មន្ទីរកសិកម្មខេត្តកណ្តាល

# សៀវភៅណែនាំ

# បច្ចេកទេសដាំដំណាំបន្លែ



ឆ្នាំ២០១៤

# សៀវភៅណែនាំ

# បច្ចេកទេសដាំដំណាំបន្លែ

រៀបចំដោយមន្ទីរកសិកម្មខេត្តកណ្តាល


**អ្នករៀបរៀង**

លោក អ៊ិន ចាន់យ៉ាវិទ្ធ

**អ្នកផ្តល់យោបល់ និង កែសម្រួល**

លោក ប៊ុនទួន ស៊ីមូណា

លោក លឹម ងួនគ្រុយ

លោក ហ៊ា សុផល

លោក ឡុង រ៉ា

លោក ផា ចាម

លោក ប៉ាន់ ខេមរិន្ទ

លោក ហាស់ វុទ្ធី

លោក អាង វណ្ណា



ម.ព.ឯ.ក AIDOC

Code: 247-051

Date:

Donated by:

# មាតិកា

**ដំណាំឪឡឹក**............................................................................ ០១

**១.លក្ខណៈរុក្ខសាស្ត្រ និងប្រភពដើម**........................................០១

ក.អំពីឫស........................................................................ ០១

ខ.អំពីផ្កា........................................................................ ០២

គ.អំពីផ្លែ........................................................................ ០៣

**២.លក្ខណៈបរិស្ថានរបស់ដំណាំឪឡឹក**........................................០៣

ក.កត្តាសីតុណ្ហភាព............................................................០៤

ខ.កត្តាដី........................................................................០៥

គ.របបខ្យល់ សំណើម និងទឹកភ្លៀង.......................................... ០៦

**៣.បច្ចេកទេសដាំដុះ**....................................................................០៧

ក.រដូវកាលដាំដុះ..................................................................០៨

ខ.ការរៀបចំដី..................................................................... ០៨

គ.វិធីសាស្ត្រដាំដុះ...................................................................០៩

**៤.អំពីជម្ងឺ និងសត្វល្អិត**.................................................................. ១៥

១.អំពីជម្ងឺសំខាន់ៗ................................................................ ១៥

ក.ជម្ងឺក្រាម្សៅលើស្លឹក............................................ ១៥

ខ.ជម្ងឺផ្សិតពពាលក្រោមស្លឹក.......................................១៦

គ.ជម្ងឺជាំស្លឹក ឬផ្លែ.................................................. ១៧

ឃ.ជម្ងឺរលួយពុកឫស និងដើម.................................... ១៧

ង.ជម្ងឺវីរុសដែលកើតលើស្លឹក.................................... ១៨

២.អំពីសត្វល្អិតសំខាន់ៗ........................................ ១៨

ក.ពពួកសត្វជញ្ជក់........................................ ១៨

ខ.ពពួកកាត់ស្លឹកដើម........................................ ១៩

គ.វិធានការការពារ និងកម្ចាត់........................................ ១៩

**៥.ការប្រមូលផល**........................................ ២០

**ដំណាំននោង**........................................ ២១

**១.លក្ខណៈសំខាន់នៃដំណាំននោង**........................................ ២១

**២.អំពីកត្តាដី និងអាកាសធាតុ**........................................ ២២

ក-ការជ្រើសរើសដី និងរៀបចំដី........................................ ២២

ខ-លក្ខខណ្ឌអាកាសធាតុ........................................ ២៣

**៣.វិធីសាស្ត្រដាំដុះដំណាំននោង**........................................ ២៣

ក-ការដាំដោយគ្រាប់ផ្ទាល់........................................ ២៤

ខ-ការដាំដោយកូនបណ្ដុះ........................................ ២៤

គ-ការស្រោចស្រព........................................ ២៥

ឃ-ការដោតចំណារ និងធ្វើធ្នើរ........................................ ២៥

ង-ការប្រើប្រាស់ជី........................................ ២៦

ច-ការសម្អាតស្មៅ និងជ្រុំជ្រោយដី........................................ ២៧

**៤.ជម្ងឺ សត្វល្អិត និងវិធានការការពារ**........................................ ២៧

ក-ជម្ងឺសំខាន់ៗ........................................ ២៧

ខ-សត្វល្អិតសំខាន់ៗ........................................ ២៨

គ-វិធានការការពារ និងកំចាត់........................................ ៣០

ឆ-ការដាក់ជី........................................................................ ៤៤

**២.ជម្ងឺ និងសត្វល្អិត**........................................................................ ៤៥

ក-ជម្ងឺ........................................................................ ៤៥

ខ-សត្វល្អិតសំខាន់ៗ........................................................................៤៦

គ-វិធានការការពារ........................................................................ ៤៧

**៣.ការប្រមូលផល**........................................................................ ៤៨

**ដំណាំល្ពៅ**........................................................................៥០

**១.ស្ថានភាពទូទៅ**........................................................................ ៥០

**២.បច្ចេកទេសដាំដុះ**........................................................................ ៥១

ក.រដូវកាលដាំដុះ........................................................................ ៥១

ខ.ការជ្រើសរើសពូជ........................................................................ ៥១

គ.ការរៀបចំដី........................................................................៥២

ឃ-ការដាំដុះ........................................................................៥២

ង-ការជ្រុំជ្រាយដី........................................................................ ៥៣

ច-ការប្រើប្រាស់ជីៈ........................................................................៥៣

ឆ-ការស្រោចស្រព........................................................................៥៥

**៣-ជម្ងឺ និងសត្វល្អិត**........................................................................ ៥៥

ក-ជម្ងឺសំខាន់ៗៈ........................................................................ ៥៥

ខ-សត្វល្អិតចង្រៃៈ........................................................................ ៥៨

**៤-ការប្រមូលផល**........................................................................ ៥៩

**ដំណាំនៃថាវ**............................................................................................ ៦០

**១-ស្ថានភាពទូទៅ**................................................................................ ៦០

**២-បច្ចេកទេសដាំដុះ**.................. ........................................................ ៦១

ក-រដូវកាលដាំដុះ...................................................................... ៦១

ខ-ការជ្រើសរើសពូជ.................................................................. ៦១

គ-ការជ្រើសរើស និងរៀបចំដី.................................................... ៦២

ឃ-ការដាំដុះ............................................................................... ៦៣

ង-ការស្រោចស្រព....................................................................... ៦៤

ច-ការជ្រុំជ្រោយដី និងដកស្មៅ.................................................... ៦៥

ឆ-ការដាក់ជី................................................................................ ៦៦

**៣-សត្វល្អិតចង្រៃ និងវិធានការពារ**................................................ ៦៧

**៤-ការប្រមូលផល**................................................................... ៧០

**៥-ការកែច្នៃផលិតផល**.............................................................. ៧១

ឯកសារយោង............................................................................... ៧២

# ដំណាំឪឡឹក

## ១-លក្ខណៈរុក្ខសាស្ត្រ និងប្រភពដើម



ដំណាំឪឡឹកជាប្រភេទដំណាំមួយ ដែលស្ថិតនៅក្នុងគ្រួសារ Cucurbitaceae លំដាប់ Citrullus ហើយឈ្មោះវិទ្យាសាស្ត្ររបស់វា ត្រូវបានគេកំណត់ថា Citrullus lanatus ឈ្មោះធម្មតា គឺWater melon។ ជាធម្មតាដំណាំគ្រួសារនេះភាគច្រើនដើមវល្លិ៍លូតលាស់ស្មើរពេញ១ឆ្នាំ ។ ដើមរបស់វាមានសភាពតភ្ជាប់ដោយថ្នាំង ហើយត្រង់ថ្នាំងអាចដុះចេញជាសន្លឹក ឫស ខ្នែង ព្រមទាំងផ្កា (ផ្កាឈ្មោល-ញី ) ។ ដំណាំប្រភេទនេះនៅក្នុងឆ្នាំ១៨៨២ លោក DeCandolle បានធ្វើការសម្រេចចិត្តឲ្យឈ្មោះពិតប្រាកដថា Water melon ព្រោះវាមានប្រភពនៅក្នុងតំបន់ទ្វីបអាហ្វ្រិកលើវាលខ្សាច់ស្ងួត នៃទ្វីបអាហ្វ្រិកខាងត្បូងគឺ Kalahari Desert ។

ក-<u>អំពីឫស</u>

រុក្ខជាតិក្នុងគ្រួសារ Cucurbitaceae ភាគច្រើនឫសរយាង

ជាប្រព័ន្ធឫស ដែលមានលទ្ធភាពទ្រទ្រង់ដំណាំឲ្យលូតលាស់បានល្អ ជាពិសេសគឺឫសដែលដុះចេញតាមថ្នាំងនិមួយៗ ។ តែជាទូទៅឫសកំណើតរបស់វា អាចគេចាត់ចូលជាប្រភេទឫសវែង វាអាចលូតលាស់ចូលទៅក្នុងដីបានជម្រៅពី១០-២០ស.ម ឬ លើសពីនេះអាស្រ័យលើប្រភេទដី ។

ខ-<u>អំពីផ្កា</u>

វុក្ខជាតិនេះភាគច្រើន ច្រើនតែមានផ្កា២ប្រភេទគឺផ្កាញី និង ផ្កាឈ្មោលនៅដាច់ដោយឡែកពីគ្នាក្នុងដើមតែមួយ ប៉ុន្តែផ្កាឈ្មោល (Male)ច្រើនរីកមុនផ្កាញី (Female) ភាគច្រើនស្រទាប់ផ្កាពណ៌លឿង ឬពណ៌ស មួយស្រទាប់ផ្គុំឡើងដោយស្រទាប់៥ត្របក និង មានថង់លំអងផ្កាឈ្មោលហៅថា Anther ចំនួនច្រើន ។ លក្ខណៈពិសេសដែលអាចធ្វើការបង្កកំណើតបាននៅពេលព្រឹកពីម៉ោង៧ដល់ម៉ោង១១ព្រឹក ។



គ-<u>អំពីផ្លែ</u>

ផ្លែនៅតាមថ្នាំងរបស់ដើម ផ្លែរបស់វាអាចមានទងដែលភ្ជាប់ពីដើមទៅផ្លែ តែវាមិនមានស្នែងផ្កាដូចពពួកប៉េងប៉ោះ ឬដំណាំឯទៀតឡើយ ។ ផ្លែនៅខ្ចីមានសភាពរោមៗ ហើយពេលផ្លែចំណាស់រោមទាំងនោះជ្រុះ និងពង្រីកកាន់តែធំឡើងៗ និងមានពណ៌ខុសគ្នា គឺពណ៌ស ពណ៌ត្នោត ឬ ត្នោតក្រឡា រីឯសាច់ខាងក្នុង ខ្លះមានពណ៌លឿង ខ្លះពណ៌ក្រហមពេលទុំ ។



## ២-លក្ខខណ្ឌបរិស្ថានរបស់ដំណាំឪឡឹក

កត្តាបរិស្ថានត្រូវបានរាប់បញ្ចូលកត្តាសំខាន់ៗ ជាច្រើនដូចជា ពន្លឺ សីតុណ្ហភាព ដី របបខ្យល់ សំណើមបរិយាកាស និង ទឹកភ្លៀង ។

ក-កត្តាសីតុណ្ហភាព

ជាទូទៅសីតុណ្ហភាព និងពន្លឺ វាជាកត្តាមួយដែលចូលរួមក្នុងអន្តរអំពើមួយយ៉ាងខ្លាំង ក្នុងដំណើរបាតុភូតរស្មីសំយោគ និងដំណាកដង្ហើម ដើម្បីផលិតនូវកាបូអ៊ីដ្រាត ។

ក្នុងដំណើររស្មីសំយោគ គឺជាការចូលរួមជាមួយពន្លឺចាប់យកឧស្ម័នកាបូនិក($CO_2$) បញ្ចេញនូវអុកស៊ីសែន($O_2$)។ ចំពោះដំណើររបស់បាតុភូតដំណាកដង្ហើម គឺចាប់យក $O_2$ បញ្ចេញនូវ $CO_2$ ។

ដំណាំប្រភេទនេះ ត្រូវការរយៈពេលពន្លឺចន្លោះពី១០-១២ ម៉ោង និងល្បាយពន្លឺទាំងអស់មានកំរិតពី៣០០០-៨០០០ Food-candles កាលណាពន្លឺខ្លាំងនិងរយៈពេលវែង គឺធ្វើឲ្យលើស Carbohy drates មិនអាចឲ្យចេញផ្កាបាន ។

តារាងអាហាររូបត្ថម្ភ

ក្នុងទម្ងន់១០០gដែលបរិភោគបាននៃផ្លែឪឡឹក

| ឈ្មោះបន្លែ | កាឡូរី | ជាតិទឹក% | កាបូអ៊ីដ្រាត % | ប្រូតេអ៊ីន % | ជេះ % | ការ៉ូតែន µg | វីតាមីនB (mg) | | វីតាមីន C (mg) | ធាតុរ៉ែ (mg) | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ស្យាមីន | ផ្លាវីន | | Ca | Fe |
| ឪឡឹកទុំ | 16 | 95,8 | 3,3 | 0,2 | 0,2 | 0 | 0,02 | 0,04 | 1 | 11 | 7,9 |

Source : Nutritive of Indiafood 1980

ចំពោះសីតុណ្ហភាពវិញ គឺចែកចេញជា៣តំណាក់កាល

នៃសេចក្ដីត្រូវការ ។ ជាទូទៅវាអាចលូតលាស់បានពី ១៥°C-៣៥°C ដំណាក់កាលដុះពន្លក គឺសីតុណ្ហភាពចន្លោះពី២០°C-២២°C ពេលចេញផ្កាចន្លោះពី២៥°C-២៧°C និងពេលទុំចន្លោះ ២៧°C-៣០°Cជាការល្អ តែបើចុះទាបជាងនេះ ឬ កើនលើសពីនេះក្នុងវគ្គនីមួយៗ វាធ្វើឲ្យការដុះលូតលាស់ខុសពីភាពធម្មតារបស់វា ។ សីតុណ្ហភាពអាចជួយបង្កើតជាតិស្ករបាននៅពេលវគ្គទុំ វាត្រូវការភាពត្រជាក់ពេលយប់យូរ ដែលសីតុណ្ហភាពចន្លោះពី២០°C-២៥°C និងពេលថ្ងៃល្មមចន្លោះពី ២៥°C-៣០°C ឪឡឹកអាចទុំពណ៌ក្រហម និងមានកំរិតភាគរយនៃជាតិស្ករច្រើន និងទុំតាមធម្មជាតិរបស់វា ។ តែបើសីតុណ្ហភាពឡើងខ្ពស់ខុសពីនេះ វាអាចធ្វើអោយទុំមិនប្រក្រតី ឬ អាចធ្វើអោយដំណាំស្រពោន ឬ ងាប់ក៏មាន ។

ខ-កត្តាដី

ដីជាកត្តាចំបាច់របស់ដំណាំសំរាប់ការដុះលូតលាស់។ ដីសំបូរទៅដោយមមោកព្រមទាំងសារធាតុរ៉ែគ្រប់គ្រាន់ អាចឲ្យការដុះលូតលាស់បានយ៉ាងឆាប់រហ័ស។ ចំពោះដំណាំឪឡឹកជាប្រភេទដំណាំ ដែលស្ថិតនៅក្នុងក្រុមធន់ទ្រាំនឹងភាពអាស៊ីតនៃដី ។ គេអាចដាំវាបានលើប្រភេទដីល្បប់តាមមាត់ទន្លេ ដីល្បាយ

ខ្សាច់ជើងភ្នំដីក្រហម (Basal) ដីខ្មៅមានគ្រួស ឬដីពណ៌ត្នោត ប៉ុន្តែវាមិនអាចដុះលូតលាស់បានល្អ លើប្រភេទដីឥដ្ឋទាំងនោះឡើយល្អបំផុតគឺដីល្បាយខ្សាច់PH ចន្លោះពី ៥,០-៦,៨ ។ ចំពោះ PH ទាបជាង៥ធ្វើឲ្យផ្លែឪឡឹកមិនអាចរីកធំបានឡើយ ព្រមទាំងធ្វើឲ្យការបង្កកំណើតមានការថយចុះ ។

គ-<u>របបខ្យល់ សំណើម និងទឹកភ្លៀង</u>

-ដំណាំនេះ ត្រូវការរបបខ្យល់បក់ខ្សោយកាលណា សីតុណ្ហភាពឡើងខ្ពស់ ខ្យល់បក់ខ្លាំង សំណើមមិនគ្រប់គ្រាន់អាចបណ្តាលឲ្យដំណាំដុះលូតលាស់យឺតគឺមកពី Stomat របស់ស្លឹកត្រូវបិទ ដើម្បីទប់ទល់នឹងរំហួតចំហាយទឹកដែលអោយឈ្មោះថា(Transpiration) ធ្វើឲ្យស្លឹកឡើងរញ៉ាម ជាពិសេសគឺដៃរបស់វាដែលហៅថា(Anterner) នេះលែងចាប់តោងអ្វីៗ ធ្វើឲ្យត្រូយរួញរបាំងខ្យល់និងផ្ទះសំណាញ់ ឬផ្ទះកញ្ចក់ ដូចជានៅអូស្រ្តាលី ជប៉ុន អាមេរិក កាណាដា និងរុស្ស៊ី ។

ម៉្យាងទៀតកាលណា ខ្យល់បក់ខ្លាំងនៅពេលចេញផ្កាគឺវាផ្អាកការដឹកជញ្ជូនជាតិទឹក ធ្វើការបន្តពូជត្រូវថយចុះភាគរយយ៉ាងច្រើន ។

***-អំពីកត្តាសំណើមៈ***សំណើមបរិយាកាស(Humidity) មានទំនាក់ទំនងយ៉ាងខ្លាំង ទៅនឹងការលូតលាស់របស់ដំណាំឪឡឹក

ពេលសំណើមបរិយាកាសឡើងខ្ពស់ចន្លោះពី ៧៥-៨៥% អាចធ្វើឲ្យដំណាំលូតលាស់លឿន ព្រោះសំណើមបរិយាកាសមានទំនាក់ទំនងទៅនឹងសីតុណ្ហភាពព្រមទាំងពន្លឺផងដែរ នៅពេលសំណើមបរិយាកាសចុះទាបចន្លោះពី ៤៥-៥៥% ធ្វើឲ្យអាកាសធាតុក្តៅហួតហែង និងអាំងតង់ស៊ីតេពន្លឺខ្លាំង ធ្វើឲ្យដំណាំបញ្ឈប់ការធ្វើរំហួតចំហាយទឹកបន្ថយការលូតលាស់ ព្រមទាំងបង្កឲ្យមានកត្តាចង្រៃទៀតផង ជាពិសេសគឺសត្វល្អិត ។

ដំណាំឪឡឹកត្រូវការសំណើមដី ជាមធ្យមចាប់ពី៨០-៨៥% នៃសំណើម (Source Fulton1986) ។

*-អំពីទឹកភ្លៀង:* ទឹកភ្លៀងជាកត្តាមួយ ដែលទាក់ទងទៅនឹង សំណើមដី និងការស្រោចស្រពដំណាំឪឡឹកមិនត្រូវការទឹកភ្លៀងខ្លាំងឡើយ ក្នុងកំឡុងពេលលូតលាស់។ តំបន់ដែលមានភ្លៀងធ្លាក់ចាប់ពី១២០០ម.ម/ឆ្នាំ គេអាចដាំបានព្រោះសំណើមដីមានលទ្ធភាពស្រូបយកជាតិទឹក ពីស្រទាប់ក្រោមមកចិញ្ចឹមរុក្ខជាតិបាន។ ប៉ុន្តែកំឡុងពេលលូតលាស់រយៈពេល៣ខែវាត្រូវការទឹកភ្លៀងសរុបប្រមាណពី១២០-១៨០ម.ម ដំណាំអាចលូតលាស់ល្អទៅបាន ។

## ៣-បច្ចេកទេសដាំដុះ

គេអាចដាំដុះដំណាំឪឡឹកលើដីច្រើនប្រភេទ ហើយវិធី

ដាំដុះក៏ទៅតាមប្រភេទដី និង រដូវកាលផងដែរ។

ក-<u>អំពីរដូវកាលដាំដុះ</u>

រដូវកាលដាំដុះរបស់ដំណាំឪឡឹក គឺអាស្រ័យទៅតាមតំបន់ នៅប្រទេសកម្ពុជា រដូវសមស្របគឺរដូវរំហើយ ចាប់ពីខែតុលា ដល់ខែមករា ឬខែកុម្ភៈ ចំពោះរដូវវស្សាវិញភាគច្រើន គេដាំ នៅតាមតំបន់ភ្នំ ឬវាលរាបមួយចំនួន ចន្លោះដូវភ្នំ គឺចាប់ពីខែឧសភា ដល់ខែសីហា។ នៅតំបន់ជុំវិញមាត់ទន្លេសាប និងទន្លេមេគង្គ អាចដាំដុះឪឡឹកនៅរដូវវស្សាមិនបានល្អឡើយ ដោយមកពីសំណើមរបស់ដីមានសភាពជោគជាំខ្លាំង និងបណ្តាលមកពីកត្តាចង្រៃមួយចំនួនទៀតដូចជាជម្ងឺ និងសត្វល្អិត ។

នៅប្រទេសចិនភាគខាងជើង គេដាំឪឡឹកនៅរដូវវស្សាល្អ គឺចាប់ពីខែមិថុនាដល់ខែកញ្ញា ចំពោះនៅប្រទេសជប៉ុនវិញគេដាំនៅខែមេសា ដល់ ខែកក្កដា ។ រីឯនៅប្រទេសថៃវិញគឺមានសភាពដូចប្រទេសកម្ពុជាយើងដែរ ។

ខ-<u>ការរៀបចំដី</u>

ការរៀបចំដីជាវិធីសាស្ត្រដ៏ចំបងមួយ ក្នុងការងារដាំដុះ។ គេអាចរៀបចំដីបានយ៉ាងច្រើនរបៀប គឺអាស្រ័យទៅលើប្រភេទដី ចំពោះដីល្បប់ល្បាយខ្សាច់គេភ្ជួរដី ក្រោយពីទឹកសម្រកស្រកផុតរយៈពេល១០-១៥ថ្ងៃ គឺដីស្ងួតល្មមចំពោះតំបន់មួយចំនួនគេ

ដាំក្រោយពីដំណាំស្រូវ គេពុំចាំបាច់ភ្ជួរដីឡើយ គឺក្រោយពីច្រូតស្រូវ ហើយគេកាប់រណ្តៅអោយបានជំរៅពី ២០-៣០ស.ម ទំហំរណ្តៅ៣០x៣០ស.ម ចំពោះចន្លោះរណ្តៅ គឺអាស្រ័យលើគោលបំណងនៃការដាំដុះ និងសក្តានុពុលរបស់ដី ។





ចំពោះការដាំដោយគ្រាប់កៅស៊ូ ឬគ្រាប់ចំបើង ក្រោយពីភ្ជួរ និងរាស់សម្រេចហើយ គឺគេឆូតលើរងនិងធ្វើចង្អូរ បន្ទាប់មកគឺគេដាក់ជីទ្រាប់បាតមានជីកំប៉ុស្ត និង ជីគីមី ដាក់រួចហើយទើបគ្រាប់កៅស៊ូ ឬ ចំបើង មុនពេលដាំដើម្បីរក្សាសំណើមដីឲ្យបានល្អ ។

គ-វិធីសាស្ត្រដាំដុះ

**គ.១ ការបណ្តុះកូន**

ការបណ្តុះកូនឪឡឹក អាចអនុវត្តបានច្រើនរបៀបនៅប្រទេសដែលសំបូរទៅដោយឧបករណ៍ គេអាចបណ្តុះនៅក្នុងកែវបណ្តុះ ថានបណ្តុះ ឬកេសបណ្តុះ ចំពោះនៅប្រទេសកម្ពុជាយើងវិញ គឺគេអនុវត្តទៅតាមលទ្ធភាពធនធានតឹកន្ទោងស្លឹក

ចេក ស្លឹកត្នោតឬកៅស៊ូដែមានរង្វង់៦ស.ម,កំពស់៨ស.ម តំរៀបជាជួរនៅកន្លែងមានពន្លឺថ្ងៃគ្រប់គ្រាន់ នៅតំបន់ត្រជាក់គេបណ្តុះកូនក្នុងផ្ទះកញ្ចក់ ឬ ផ្ទះប្លាស្ទិក។ ដីដែលយកមកបណ្តុះនោះក៏មានដីជាតិល្អ ហើយស្ងួតផ្សំជាមួយផេះអង្កាម ១ភាគ ស្រកីដូង ១ភាគ សរុបចូលគ្នាទម្ងន់១០០គ.ក្រ ត្រូវលាយជាមួយដី $P_2O_5$ 43%ចំនួនពី១-២គ.ក្រ ឬដី DAPចំនួន១-១.៥គ.ក្រ ឬដី ១៥-១៥-១៥ ចំនួន២គ.ក្រ រឺឯកំប្លោកចំនួន២គ.ក្រ ថ្នាំកសិកម្មលាយបញ្ចូលគ្នាឲ្យសព្វ ទើបច្រកចូលក្នុងឧបករណ៍ខាងលើឲ្យបាន 2/3 នៃកំពស់របស់ឧបករណ៍ទាំងនោះ ។ ក្រោយមកត្រូវយកគ្រាប់ពូជមកដាក់ហាលថ្ងៃរយៈពេលពី១-២ម៉ោង បន្ទាប់មកយកមកត្រាំជាមួយសូលុយស្យុងថ្នាំផ្សិត លាយកូឲ្យល្បាយស្មើសាច់ ហើយទើបចាក់គ្រាប់ត្រាំរយៈពេល២០-៣០នាទី ទើបយកទៅដាក់បណ្តុះពី៣-៤គ្រាប់/កន្ទោង ក្រោយមកទើបលប់បំពេញ ដោយដីផ្សំទាំងនោះពីលើឲ្យពេញហើយគ្របចំបើង ឬសំណាញ់អោយជិតពីលើ ហើយស្រោចទឹក២ដង/ថ្ងៃ ។ រយៈពេល២ថ្ងៃ គេអាចយកចំបើង ឬយកសំណាញ់ចេញ ក្រោយពីបណ្តុះ រយៈពេល៥ថ្ងៃ គេអាចយកទៅដាំបានយ៉ាងល្អប្រសើរ ។ ក្នុងផ្ទៃដី១ហិកតា គេប្រើប្រាស់គ្រាប់ ចំនួនពី៣.៥-៥គ.ក្រ គ្រាប់ឪឡឹកចំនួន១០០០គ្រាប់ អាចមានទំងន់ពី៥៥-៦០ក្រាម មុននិង

យកទៅដាំគេត្រូវបាញ់ថ្នាំជាមុន គឺប្រភេទថ្នាំគីមីពុលលាយជាមួយប្រភេទថ្នាំផ្សិតដើម្បីការពារពួកជម្ងឺនិងសត្វល្អិត ។



ដើម្បីឲ្យដំណាំដុះលូតលាស់ស្មើគ្នាល្អ គឺត្រូវជ្រើសរើសកូនឪឡឹកដែលធំថ្លោសល្អ មុននឹងលើកកូនយកទៅដាំ គឺត្រូវស្រោចទឹកឲ្យជោគរយៈពេល២០-៣០នាទី ទើបគេយកកូនទៅដាំបាន ។

-ការដាំដោយស្រោចស្រពៈ គឺគេលើករងឲ្យខ្ពស់កំពស់ពី៣០-៣៥ស.ម ចំងាយពីជួរមួយទៅជួរមួយ២.៥ម ចន្លោះគុម្ពពី៩០-១២០ស.ម ដាំ២ដើម/គុម្ព ។

-ការដាំដោយកាប់រណ្តៅនៅក្នុងស្រែៈ ការដាំតាមវិធីនេះគេមិនភ្ជួរឡើយ តែគេកាប់ជារណ្តៅក្នុងស្រែឬចំការចន្លោះជួរពី២-២.៥ម ចន្លោះរណ្តៅពី១០០-១៥០ស.ម ដាំ២ដើម/គុម្ព ។ មុន

ដាំគេយកជី១៥-១៥-១៥ចំនួន២០០គ.ក្រ/ហិកតា លាយជាមួយថ្នាំកសិកម្មបញ្ចូលគ្នា ហើយដាក់តាមបាតរណ្ដៅមុនពេលដាំ ដើម្បីការពារពួកសត្វល្អិតក្នុងដី និងឲ្យដំណាំដុះលូតលាស់លឿន ។

### គ.៣ ការស្រោចស្រព



ការស្រោចស្រពដោយដំណក់ទឹក

ដំណាំឪឡឹក មិនត្រូវការទឹកខ្លាំងដូចត្រសក់ចំណារឡើយ ក្នុងតំណាក់កាលលូតលាស់ ។ ក្រោយពីដាំរហូតដល់ពេលចេញផ្កា វាត្រូវការសំណើមដីប្រមាណ៦៥-៧០% ជាប្រចាំប៉ុណ្ណោះ តែបើគេប្រើវិធីសាស្ត្របញ្ចូលទឹក គឺគេបញ្ចូល២ដង/

សប្តាហ៍ ចំពោះការស្រោចដោយដៃផ្ទាល់ ឬដោយSprinklerគឺ១ដង/ថ្ងៃ។ ក្រោយពីដំណាំអាយុពី២០-២៥ថ្ងៃ។ ដល់ពេលចេញផ្កាដំបូងដំណាំត្រូវការទឹកកាន់តែខ្លាំង ដូច្នេះការស្រោចស្រពត្រូវបង្កើនបរិមាណទឹក និងចំនួនដងនៃការបញ្ចូលដើម្បីរក្សាសំណើមដីឲ្យមានលំនឹងចន្លោះពី៨០-៨៥% ។

គ.៤ <u>ការប្រើប្រាស់ជី</u>

ការប្រើប្រាស់ជីនៅលើដំណាំឪឡឹក គឺអាស្រ័យទៅលើប្រភេទដី ប្រភេទពូជ និងដង់ស៊ីតេដំណាំ។ តំណាក់កាលលូតលាស់ដំបូងដំណាំត្រូវការអាសូត(N)បន្ទាប់មកវាត្រូវការផូស្វ័រ(P) ដើម្បី ពន្លកដើមចេញឫស ព្រមទាំងធ្វើឲ្យឫសមានកំលាំងរឹងមាំធានាដល់ការដឹកជញ្ជូនជាតិទឹក និងសារធាតុចិញ្ចឹមផ្សេងៗ។ ចំពោះប៉ូតាស្យូម (K) វិញ ដំណាំមិនអាចខ្វះបានដែរ ប៉ុន្តែបើកាលណាលើស K វាធ្វើឲ្យរំខានដល់ការដឹកជញ្ជូនសារធាតុផ្សេងៗ K អាចជួយទប់ទល់នូវអំពើផ្សេងៗ របស់ធម្មជាតិ ព្រមទាំងជួយបង្កើតនូវពន្លកមើម និងរសជាតិរបស់ដំណាំ ។

✦<u>វិធីប្រើប្រាស់ជី</u>

-ជីកំប៉ុស្ត ចំនួនពី ៧-១០តោន/ហិកតា

-ជី១៥-១៥-១៥ ចំនួន២០០គ.ក្រ ទ្រាប់បាតមុនពេលដាំ

-បំប៉នជីអ៊ុយរ៉េ៤៦% ចំនួន៥០គ.ក្រ លាយទឹកស្រោច

ក្រោយដាំចំនួន ១០ថ្ងៃ

-បំប៉នជី១៥-១៥-១៥ ចំនួន១៥០គ.ក្រ លាយជាមួយជី DAP ចំនួន១០០គ.ក្រ ដាក់តាមចន្លោះគុម្ព ឬជុំវិញគល់ក្រោយពីដាំបានរយៈពេល២៥ថ្ងៃ ។

-បំប៉នចុងក្រោយគឺជីប៉ូតាស្យូមក្លរូ (Kcl) ចំនួន៨០គ.ក្រ/ហិកតា ក្រោយពីដាំបាន៤៥-៥០ថ្ងៃ គឺឪឡឹកចាប់ផ្ដើមពង្រីកផ្លែក្រោយពីបង្កាត់រួច។ សរុបរូបមន្តជីគឺ $N_{93}$ $P_{98}$ $K_{100}$/ហិកតា ។

គ.៥ <u>ការកំចាត់ស្មៅ ជ្រុំដីពូនគល់និងកាត់មែក</u>

ដំណាំអាចដុះលូតលាស់បាន ក្នុងករណីការដាំដុះត្រូវបានគេចាប់អារម្មណ៍ទៅលើគ្រប់វិធីសាស្ត្រ នៃការដាំដុះរបស់វាដូចជាការជ្រុំជ្រោយដីឲ្យធូរដើម្បីប្ដូរអុកស៊ីសែន ($O_2$) បានល្អព្រមទាំងវិធានការកាត់រំលោះមែកចោល ឬមួយចំនួនរក្សាត្រឹមសមាមាត្រនៃការចិញ្ចឹម និងលូតលាស់ ។

***<u>-វិធានការកម្ចាត់ស្មៅ</u>***

ការកម្ចាត់ស្មៅ គេអាចប្រើថ្នាំកម្ចាត់ស្មៅ។ ចំពោះវិធីសាស្ត្រសាមញ្ញ គឺក្រោយដាំរយៈពេលពី១០-១៥ថ្ងៃ គេជ្រុំជ្រោយដីកំចាត់ស្មៅលើកទី១ ដោយចបជំរះស្មៅធម្មតាលើកទី២ គឺក្រោយដាំបាន២៥-៣០ថ្ងៃការកាត់ និងប្រមូលយកស្មៅចេញ ហាមជ្រុំជ្រោយដីធ្វើឲ្យឫសដំណាំរំខានក្នុងការជញ្ជូន

សារធាតុចិញ្ចឹម ។

*-ការជ្រុំជ្រោយដី ពូនគល់*

គេអាចជ្រុំដីឲ្យផុស ហើយពូនលប់គល់ ឬក៏លប់ថ្នាំង បន្ថែមទៀត ដើម្បីឲ្យថ្នាំងនោះដុះឫសថ្មីជំនួយដល់ការដុះលូតលាស់បន្ថែមទៀត។ គេអាចធ្វើបាននៅពេលឪឡឹកមានអាយុ ១០-១៥ថ្ងៃ ក្រោយដាំមុននឹងជ្រុំដី លប់គល់គេត្រូវកាត់ស្លឹក ចំនួន៤-៥សន្លឹក នៅផ្នែកខាងគល់ និងខ្នែងដែលដុះចេញពីគល់ ត្រូវកាត់ចោលរក្សាតែដើមមេមួយប៉ុណ្ណោះ ទើបលប់ដីនៅផ្នែក គល់ព្រមទាំងកូនឲ្យខ្ពស់បន្តិច។ រយៈពេល២-៣ថ្ងៃក្រោយពីពូន គល់ គឺគេកាត់ត្រួយដើមមេចោល ដោយឲ្យខ្នែង២ដុះចេញពី ដើមមេ ចំពោះផ្កាដែលដុះចេញពីខ្នែងទាំង២គេអាចរក្សាផ្កាយក ជាផ្លែបាន ប៉ុន្តែរងចាំនៅថ្នាំងទី៧-៨ បន្ទាប់ពីការបែកពីដើមមេ ទៅ ។ ដើម្បីឲ្យឪឡឹកផ្លែធំថ្លោស ហើយស្មើគ្នា គេទុកមួយមែក មួយផ្លែក្នុងមួយដើមគេទុកផ្លែតែ២ មួយគុម្ពអាចទុកបានផ្លែចំនួន ៤ ។ ធ្វើវិធីនេះផ្លែឪឡឹកទុំស្រុះធំស្មើគ្នា ។

## ៤-អំពីជម្ងឺ និងសត្វល្អិត

១-<u>អំពីជម្ងឺសំខាន់ៗ</u>

*ក/<u>ជម្ងឺក្រាម្សៅលើស្លឹក</u>* **Powdery Mildew**

ជម្ងឺនេះបំផ្លាញយ៉ាងខ្លាំងក្លា ទៅលើប្រភេទរុក្ខជាតិក្នុង

គ្រួសារ Cucurbitaceae and Leguminosae ជាពិសេសនៅរដូវត្រជាក់ស្ងួតគ្មានភ្លៀង លក្ខខណ្ឌចំការមានអាកាសធាតុមិនគ្រប់គ្រាន់ ពិសេសនៅក្បែរចំការព្រៃទាំងឡាយ ។ វាបង្កឡើងដោយមេរោគឈ្មោះ Sphaero the cafuliginea ។ រោគសញ្ញាដំបូង គឺគេឃើញចំណុចផ្សិតសនៅលើផ្ទៃស្លឹកផ្នែកខាងលើ ក្រោយមកផ្សិតទាំងនោះរីករាលលើផ្ទៃស្លឹក ដោយជាប់គ្នាពាសពេញស្លឹកធ្វើឲ្យដំណាំបន្ថយការធ្វើរស្មីសំយោគ ក្រោយមកប្រែពណ៌ទៅជាពណ៌ត្នោតហើយខ្លោចស្លឹក ក្នុងតំណាក់កាលនេះអាចបែកហុយពេញចំការ គេប្រើថ្នាំផ្សិតបាញ់នៅពេលឃើញមានរោគសញ្ញាទើបកើតឡើង ។

## ខ-ជម្ងឺផ្សិតពពាលក្រោមស្លឹក

ជម្ងឺនេះបង្កឡើងដោយផ្សិតឈ្មោះ Pseudo peronospora cubensis ច្រើនកើតឡើងនៅលើពួកCucur-bitaceaeដូចជាត្រសក់ចំណារ ត្រសក់ស្រូវ ឃ្លោក ជាពិសេសកើតឡើងនៅពេលសំណើមបរិយាកាសខ្ពស់ និងមានភ្លៀងធ្លាក់នៅរដូវប្រាំងជាហេតុបង្កឲ្យកើតជម្ងឺនេះយ៉ាងរហ័ស ។

ដំបូងលេចឡើងចំណុចពព្រុសលើផ្ទៃស្លឹក ក្រោយមកទៅជាពណ៌ពពាលលឿង ឬត្នោតខ្ចី ក្រោយមកវារីករាលដាលជាប់គ្នាលើផ្ទៃស្លឹក ធ្វើឲ្យស្លឹកខ្លោចរមូរហើយជ្រុះ ធ្វើឲ្យដំណាំ

បាត់បង់ការលូតលាស់១០០% ។

*គ-ជម្ងឺដាំស្លឹក ឬ ផ្លែ*

ជម្ងឺនេះបង្កឡើងដោយសារមេរោគឈ្មោះColletotrichum sp វាតែងរាតត្បាតបំផ្លាញលើផ្លែ ស្លឹក ស្ទើរគ្រប់រុក្ខជាតិ ដំបូងគេឃើញចំណុចនោះរីកធំឡើងៗ ហើយច្រេះស្ងួត ហើយផ្ទៃខាងៗជុំវិញជម្ងឺមានសភាពស្ងួតពណ៌ស វាធ្វើឱ្យបន្ថយការលូតលាស់ពេលកើតលើដើម ស្លឹក ការកើតលើផ្លែធ្វើឲ្យផ្លែស្ងួតៗសំបក ហើយផតចូលត្រង់កន្លែងផតនោះប្រេះបន្តិចៗ ។

*ឃ-ជម្ងឺរលួយពុកឫស និង ដើម*

ប្រភេទជម្ងឺរលួយពុកឫស និងទន់ដើមនេះកើតលើគ្រប់រុក្ខជាតិ ជាពិសេសកត្តាអាកាសធាតុសមស្របសម្រាប់ការលូតលាស់ និងរីកចំរើនជម្ងឺនេះដូចជាសំណើមដីខ្ពស់សំណើមបរិយាកាសខ្ពស់ ។ ជម្ងឺនេះបណ្ដាលមកពីមេរោគប្រភេទ Fusarium oxysporum wilt ជាបណ្ដាញតូចៗរបស់ Niveum ។ វាបំផ្លាញគ្រប់ដំណាក់កាលរបស់ដំណាំ គឺតំណាក់កាលកូនដំណាំនៅតូចធ្វើឲ្យទន់គល់ និង រលួយចំពោះដំណាំពេញវ័យគឺវាធ្វើឲ្យដំណាំដំបូងចាប់ផ្ដើមប្រែពណ៌បន្តិចៗ ហើយស្រពោនពេលនោះគល់ ឬ ឫស មានសភាពជាំដុំៗផ្នែកសំបក អាចឲ្យដំណាំងាប់យ៉ាងរហ័ស។ សីតុណ្ហភាពដីចន្លោះពី ៣២-៣៣$^0$C រិតតែបង្កើនភាព

ធន់ទ្រាំរបស់ជម្ងឺប្រភេទនេះ។ គេប្រើថ្នាំផ្សិតបន្ថយការប្រើជីអាសូត (N) និង បន្ថយការស្រោចទឹក ។

*ង-ជម្ងឺវីរុសដែលកើតលើស្លឹក*

គេហៅឈ្មោះធម្មតាថា ជម្ងឺរួញស្លឹកមានចំរៀកដូចស្លឹកល្ហុងគឺPapaya ring spot mosaic Virus។ ជម្ងឺនេះច្រើនធ្វើឲ្យស្លឹកឡើងរមួរ ជាពិសេសពីចុងដំបូងគឺរួញត្រួយ ក្រោយមករមួរស្លឹកចុះក្រោមហើយធ្វើឲ្យខ្លោចស្លឹកបន្ថយការលូតលាស់បន្តិចម្តងៗ ប្រសិនបើក្នុងតំណាក់កាលផ្លែ ធ្វើឲ្យផ្លែមិនរីកធំថ្លោសបានឡើយ ។ ដំបូងគេពិនិត្យឃើញ សត្វល្អិតដូចជាៈ រុយស មមាចខៀវ និងចៃជាភ្នាក់ងារចម្លងជម្ងឺនេះ។ ដូច្នេះការបាញ់ថ្នាំសម្លាប់សត្វល្អិត៥-៧ថ្ងៃម្តង ដើម្បីកំចាត់សត្វល្អិតទាំងនេះជាការល្អ ព្រោះជម្ងឺនេះកើតពីពួកសត្វចម្លងជម្ងឺ។ ការដកចោលនូវដើមកើតជម្ងឺចេញឲ្យឆ្ងាយពីចំការជាការប្រសើរ ។

ដំណាំប្រភេទនេះទទួលរងនូវជម្ងឺផ្សេងៗ ជាច្រើនទៀតដូចជាពពួកជម្ងឺវីរុស ដែលបង្កឲ្យពកហើមឫសទាំងអស់ធ្វើឲ្យការលូតលាស់យឺត ផ្លែមិនរីកធំ ស្លឹកបៃតងចាស់ និងរួញ គឺបណ្តាលមកពីជម្ងឺ Root-Knot of water melon ។

២-<u>អំពីសត្វល្អិតសំខាន់ៗ</u>

*ក-ពពួកសត្វជញ្ជាក់*

-ចៃគ្រប់ប្រភេទ ( Aphids ) ពួកមមាច( Hoppers )ក្រុមទ្រីប ( Thrips)

-ក្រុមរុយ White fly and Dancus sp រុយលើដំណាំហូបផ្លែ

***ខ-<u>ពពួកកាត់ស្លឹក ដើម</u> Plant and Leaf damage***

-ដង្កូវហ្វូងឈ្មោះ(Spodoptera sp)ដង្កូវចោះផ្លែ(Helicoverpa Armygera)

-ដង្កូវស៊ីផ្កាឈ្មោះ(Maruca testulalis)ដង្កូវកាត់ដើមឈ្មោះ (Agrotes or Cutworm)

-ដង្កូវមូរស្លឹក Leaf roller ដង្កូវចូលក្នុងស្លឹក ឬ ដង្កូវស៊ីញៀ ឈ្មោះ(Leaf miner)

***គ-<u>វិធានការការពារ និង កំចាត់</u>***

-ការកំចាត់ស្មៅ កាត់ស្លឹក ដង់ស៊ីតេដើមក្នុងចំការសមស្របអាចបន្ថយជំរកសត្វ និង ការបំផ្លាញ

-ការជ្រើសរើសរដូវសមស្រប គឺកាត់បន្ថយកំណើននូវប្រជាកររបស់សត្វចង្រៃ

-ការជ្រើសរើសពូជធន់ អាយុកាលល្វតលាស់ខ្លីជាមធ្យោបាយដ៏ល្អ

-វិធានការគីមី គឺជាវិធានការចុងក្រោយដូចជាថ្នាំ Diazinon, Delthamethrin គួរតែបាញ់១អាទិត្យម្តង នៅពេលពិនិ

ត្យឃើញមានមេអំបៅហើរច្រើនក្នុងចំការ ពិសេសពេលព្រលប់ ព្រោះវាច្រើនចេញពន្ធពូជ និងស៊ីបំផ្លាញនៅពេលយប់ ។

## ៥-ការប្រមូលផល

គេអាចប្រមូលផលឪឡឹកបាន នៅពេលផ្លែរបស់វាទុំគឺ សាច់ខាងក្នុងផ្លែប្រែពីពណ៌សទៅក្រហមផ្កាឈូក ឬទៅជាពណ៌ លឿងអាស្រ័យតាមប្រភេទពូជ ។ គេអាចសំគាល់ផ្លែឪឡឹកទុំ ឬ មិនទុំ អាស្រ័យទៅលើអាយុកាលរបស់វា ពូជស្រាលគឺ៦៥ថ្ងៃ ក្រោយដាំ ពូជមធ្យមពី៧៥-៨០ថ្ងៃក្រោយដាំ ពូជធ្ងន់ពី៩០-៩៥ ថ្ងៃក្រោយដាំ គឺដៃនៅក្បែរទងស្ងួតដល់ដើម១០០% គឺផ្លែអាច ប្រមូលផលបាន ពេលខ្លះគេសំគាល់សូរសំឡេងគោះផ្លែបែប ស្រាល ពេលនោះឪឡឹកអាចល្មមបេះគឺគេកាត់យកត្រឹមទង ក្បែរដើម អាចរក្សាទុកផ្លែឪឡឹកបានយូរថ្ងៃ ។ ក្រោយពីបេះ ហើយហាមដាក់ហាលថ្ងៃ បណ្តាលឲ្យឪឡឹកប្រេះផ្លែទុកមិន បានយូរ ។



# ដំណាំននោង

## ១-លក្ខណៈសំខាន់នៃដំណាំននោង



ននោង ជាដំណាំប្រពៃណីមួយ ដែលដុះ និងលូតលាស់ពេញមួយឆ្នាំ ហើយវាមានលទ្ធភាពវារតោងឡើងរុក្ខជាតិដ៏ទៃ ដោយភាពជាវល្លិរបស់ដើម។ ដំណាំនេះត្រូវបានគេជឿជាក់ថា វាមានអាយុយ៉ាងចំណាស់ នៅលើផែនដីយើងជាង៣០០០ឆ្នាំមកហើយ តាមការស្រាវជ្រាវ របស់អ្នកក្សេត្រវិទូនៅមជ្ឈមណ្ឌលស្រាវជ្រាវរុក្ខជាតិ នៅទ្វីបអាហ្វ្រិក និងទ្វីបអាស៊ី ។ ក្រុមអ្នកវិទ្យាសាស្ត្រ រាប់បញ្ចូលទៅក្នុងគ្រួសារ **Cucurbitaceae** លំដាប់ **Cucurbits**ហើយចែកចេញជា៨២៥ប្រភេទ ដំណាំនេះស្ថិតនៅក្នុងប្រភេទ **Luffa species** ដែលមានឈ្មោះវិទ្យាសាស្ត្រហៅថា **Luffa Cylindrica Roem** និង តំបន់ខ្លះទៀតគេសរសេរឈ្មោះថា **Loofah** ឈ្មោះធម្មតា **Sponge gourd** ។ តាមប្រវត្តិនៃ

ការដាំដុះដំឡូងអង្វែងរបស់វាគឺ គេកំណត់ថា ៖ មានប្រភពដើម នៅក្នុងតំបន់ក្តៅគឺអាស៊ី និង អាហ្វ្រិក ។

## ២-អំពីកត្តាដីនិងអាកាសធាតុ

អំពីដី និង អាកាសធាតុជាកត្តាចាំបាច់សំរាប់ការដាំដុះ ព្រោះដំណាំនីមួយៗត្រូវការប្រភេទដីផ្សេងៗពីគ្នា និងលក្ខខណ្ឌ អាកាសធាតុផ្សេងពីគ្នាដែរ ។

ក-ជ្រើសរើសដី និងការរៀបចំដី

ដំណាំនេះសមស្របទៅលើដីស្ទើរគ្រប់ប្រភេទ គេអាច ដាំវាលើប្រភេទដីជូរ និងដីប្រៃPH ចន្លោះពី៤,៥-៨,៥ ហើយ វាអាចធានាការសើមខ្លាំងរបស់ដីរហូតដល់ ៩២-៩៣% នៃ សំណើម ។ កត្តាសំខាន់គឺមានប្រភពទឹកគ្រប់គ្រាន់ ព្រោះវា មានរយៈពេលលូតលាស់វែងស្ទើរពេញមួយឆ្នាំ ។ គេអាចដាំលើ ដីទំនាបដូចស្រែបាន គ្រាន់តែលើកទួលផុតពីទឹកកំពស់ពី១០-១៥ស.ម ។



ទិដ្ឋភាពចម្ការននោង

ចំពោះការរៀបចំដី គឺគួរតែភ្ជួរឲ្យបានជ្រៅជំរៅពី២០-៣០ស.ម ហើយរាស់បំបែកដី ឲ្យហ្មត់ទើបលើករង ដែលមានទទឹងពី ១០០-១២០ស.ម កំពស់រងពី ២៥-៣០ស.ម ។ ដើម្បីងាយស្រួលធ្វើផ្ទើរឲ្យដំណាំវារតោងឡើង គេត្រូវឲ្យឃ្លាតពីរងមួយ ទៅរងមួយទៀតពី៣-៣,៥ម ។ មុនពេលលើករង គេយកជីធម្មជាតិ និងជីគីមីទៅដាក់ ហើយពូនលប់ឲ្យជិតដើម្បីឲ្យសំណើមនឹងជីជាតិបានយូរ ។

ខ-<u>លក្ខខណ្ឌអាកាសធាតុ</u>

វាត្រូវការសីតុណ្ហភាពក្ដៅពី ២៥-៣៥$^0$C ដើម្បីដុះលូតលាស់ និងបង្កើតជាផ្លែ ។ វាពុំត្រូវការសីតុណ្ហភាពទាបជាង ១៨$^0$Cឡើយ ព្រោះធ្វើឲ្យគ្រាប់មិនអាចដុះបាន និងចំពេលចេញផ្កាធ្វើឲ្យផ្កាជ្រុះ និងបាត់បង់បរិមាណផលយ៉ាងច្រើន។ ចំពោះដំណាំប្រភេទ **Cucurbits** វាមិនត្រូវការខ្យល់បក់ខ្លាំងនោះឡើយ ធ្វើឲ្យការលូតបោះទងមិនបានល្អ ។ ចំពោះសំណើមបរិយាកាសវិញសមស្របចន្លោះពី៧០-៨៥% ។

## ៣-វិធីសាស្ត្រដាំដុះដំណាំននោង

មុននិងធ្វើការដាំដុះ គេគួរតែធ្វើការជ្រើសរើសពូជជាមុនសិន ពូជខ្លះប្រកាន់រដូវពូជខ្លះទៀត មិនប្រកាន់រដូវ គេអាចដាំននោងបាន២របៀប អាស្រ័យទៅលើចំណង់ចំណូលចិត្ត និង

លក្ខខណ្ឌបរិស្ថាន ចំពោះការដាំជាលក្ខណៈគ្រួសារ គេច្រើនដាំដោយគ្រាប់ផ្ទាល់ឬដោយកូនបណ្ដុះ តែចំពោះដាំជាលក្ខណៈផលិតកម្មធំៗគឺគេដាំដោយគ្រាប់ផ្ទាល់ជាការងារងាយស្រួល ។

ក-ការដាំដោយគ្រាប់ផ្ទាល់

ក្រោយពីការលើករង និង ដាក់ជីរួចហើយ គេត្រូវយកគ្រាប់ននោង ទៅដាក់ហាលថ្ងៃ ឲ្យក្ដៅពី ១-២ម៉ោង ហើយត្រាំទឹករយៈពេល ១យប់(១២ម៉ោង)ហើយយកទៅផ្អាប់រយៈពេលពី ២-៣ថ្ងៃ ក្រោយពីការដុះពន្លកហើយទើបគេយកទៅដាំលើរងដោយកប់ជំរៅពី៣-៤ ស.ម ហើយដាក់ជីកំប៉ុស្ដ ឬ កំណាត់ចំបើងគ្របពីលើទើបស្រោចទឹកតាមក្រោយ ។ ចន្លោះពីគុម្ព១ទៅគុម្ព១ទៀតប្រមាណពី ២០-៣០ស.ម ១គុម្ព ដាំ២ដើម ។

ខ-ការដាំដោយកូនបណ្ដុះ

ក្រោយពីផ្អាប់ ដូចករណីទី១ហើយ គេយកទៅបណ្ដុះក្នុងកន្ទោង ឬ ថានបណ្ដុះរយៈពេលពី៤-៥ថ្ងៃ កូនននោងចេញសន្លឹកកំណើតទី២ គេអាចយកទៅដាំបាន ។ គេមិនអាចទុកអោយននោង ចេញស្លឹកពិត ឬ ចេញផ្លែទើបយកទៅដាំនោះទេ ព្រោះវាធ្វើឲ្យការលូតលាស់យឺត ។ ចំពោះចន្លោះគុម្ព និង ចំនួនដើមដូចគ្នាទៅនឹងករណីទី១ដែរ ។

គ-ការស្រោចស្រព

ដំណាំននោងត្រូវការទឹកជាងដំណាំ ឃ្លោក ត្រសក់ និង ល្ពៅ គេអាចបញ្ចូលទឹកឲ្យជោគខ្លាំង១អាទិត្យពី២-៣លើក ជាពិសេសនៅពេលចេញផ្កា ។ ពូជស្រាលមិនប្រកាន់រដូវ ចេញផ្កាអាយុពី២៨-៣២ថ្ងៃក្រោយដាំ ចំពោះពូជធ្ងន់ជាពូជប្រកាន់រដូវ វាអាចចេញផ្កានៅរដូវជាក់លាក់របស់វា ដូចជាពូជក្នុងស្រុក (៩០-១២០ថ្ងៃ) ក្រោយដាំទើបចេញផ្កា ពិសេសនៅចុងឆ្នាំបញ្ចប់រដូវ ។

ឃ-ការដោតចំណារនិងធ្វើផ្នើរ

ដំណាំននោងគេមិនចូលចិត្តដាំឲ្យវារផ្ទាល់ដីឡើយ ធ្វើឲ្យផ្លែមិនមានភាពត្រង់តាមលក្ខណៈក្បេត្រវិទ្យារបស់វាឡើយ គេតែងតែដោតចំណារឲ្យកោងឡើង និង ធ្វើផ្នើរឲ្យវាលូតលាស់តាមលក្ខណៈរុក្ខសាស្ត្ររបស់ដំណាំ ។ ក្រោយពីដាំរយៈពេលពី ១០-១២ថ្ងៃ វាបោះទងចេញដៃ សំរាប់តោងឡើង ដូច្នេះ គេគួរតែធ្វើនៅពេលនោះជាការប្រសើរ។ កំពស់ផ្នើរធ្វើឲ្យផុត



ពីដីកំពស់ពី១,៨-២ម ដើម្បីឲ្យស្រឡះខ្យល់ចេញចូលល្អ ការពារពពួកសត្វល្អិតចង្រៃ និងជម្ងឺផ្សេងៗ ។

ង-<u>ការប្រើប្រាស់ជី</u>

ដំណាំននោងត្រូវការជីជាតិ ដូចដំណាំដ៏ទៃទៀតដែរ ដើម្បីការលូតលាស់។ ក្នុងតំណាក់កាលដំបូងវាត្រូវការជាតិអាសូត (N) បន្ទាប់មកទៀតទើបត្រូវការជាតិផូស្វ័រ (P) និងត្រូវការជាតិប៉ូតាស្យូម (K) ដើម្បីការលូតលាស់ប្រព័ន្ធឫស លូតលាស់ប្រវែងដើម ស្លឹក និង ការចេញផ្កា ផ្លែ ដើម្បីឲ្យការលូតលាស់បានសមស្រប គេចែកចេញការដាក់ជីមាន ៤ ដំណាក់កាលដូចខាងក្រោម៖

-ដាក់ទ្រាប់បាត: ជីកំប៉ុស្តចំនួន ៥-៦ តោន /ហិកតា និងជី១៥-១៥-១៥ ចំនួន១០០-១៥០គ.ក្រក្នុង១ហិកតា ឬ ជីDAP ចំនួន ១០០-១២០ គ.ក្រ / ហិកតា ។

-ដាក់បំប៉នលើកទី១: ក្រោយដាំពី១០-១២ថ្ងៃ ដោយប្រើជីអ៊ុយរ៉េចំនួន ៥០-៦០គ.ក្រ/ហិកតា

-ដាក់បំប៉នលើកទី២: ក្រោយដាំពី ២០-២៥ថ្ងៃ ដោយប្រើជី ១៥-១៥-១៥ ចំនួន ១០០-១២០គ.ក្រ ក្នុង១ហិកតាដាក់តាមចន្លោះគុម្ព ហើយកប់អោយជិតទៅក្នុងដី ។

-ដាក់បំប៉នលើកទី៣៖ ក្រោយពីប្រមូលផលបានពី ២-៣

លើក គឺ ៦៥-៧០ថ្ងៃ ក្រោយដាំ ដោយប្រើជី ១៥-១៥-១៥ ចំនួន ១០០ គ.ក្រ / ហិកតា លាយជាមួយជីអ៊ុយរ៉េចំនួន ៥០ គ.ក្រ / ហិកតា ដាក់តាមចន្លោះគុម្ពហើយបញ្ចូលទឹកភ្លាម ។

ច-<u>ការសំអាតស្មៅនិងជ្រុំជ្រោយដី</u>

ការសំអាតស្មៅ និង ជ្រុំជ្រោយដី ត្រូវធ្វើឡើងចំនួនពី ២-៣លើក ដើម្បីបំផ្លាញចោលនូវជំរកសត្វល្អិត និង ធ្វើឲ្យដីធូរងាយស្រួលដំណាំលូតលាស់បានល្អ ។

## ៤-ជម្ងឺ សត្វល្អិត និងវិធានការការពារ

ក-<u>ជម្ងឺសំខាន់ៗ</u>

ដំណាំននោងភាគច្រើន មិនទទួលរងការបំផ្លាញដោយជម្ងឺធ្ងន់ធ្ងរឡើយ ជម្ងឺសំខាន់ដែលបំផ្លាញមានដូចជា៖

ក-១<u>ក្រុមជម្ងឺផ្សិត</u>

ប្រភេទជម្ងឺនេះច្រើនតែកើតឡើង នៅក្រោមលក្ខខណ្ឌអាកាសធាតុក្ដៅសើមគ្មានពន្លឺគ្រប់គ្រាន់ ដូចជាជម្ងឺរលួយគល់ និង ឫសឈ្មោះ **Luffa Reotrot** ជម្ងឺនេះភាគច្រើនបំផ្លាញក្នុងតំណាក់ កាលដុះលូតលាស់ដំបូង ។ ជម្ងឺរលួយផ្លែឈ្មោះ **Fruit Rot** ជម្ងឺនេះច្រើនតែធ្វើឲ្យផ្លែននោងស្អុយរលួយ នៅក្រោយពេលផ្កាញី និង ផ្កាឈ្មោលបង្កាត់ហើយមានរាងជាផ្លែពិតប្រាកដ ពេលខ្លះវាបំផ្លាញកេសរផ្កាកំពុងបង្កកំណើតក៏មាន

ពិសេសនៅពេលដាំញឹក ស្លឹកទ្រុបទ្រុលខ្លាំង ។

ក-២ ក្រុមជម្ងឺវីរុស

ជម្ងឺនេះ គេសង្កេតឃើញការបំផ្លាញរបស់វានៅពេលននោងជិតចេញផ្កា គឺបណ្ដាលមកពីពពួកសត្វល្អិត ជាភ្នាក់ងារចម្លងបំផ្លាញ តាំងពីដំណាក់កាលលូតលាស់ដំបូង ប៉ុន្តែកសិករពុំបានចាប់អារម្មណ៍ទៅលើការបំផ្លាញនោះឡើយ ដូចជាពពួកចៃ ទ្រីប និងមមាច ធ្វើឲ្យស្លឹករួញ លែងលូតលាស់ដូចជា **Luffa Mosaic Virus** បានកំណត់ឈ្មោះដោយលោក **Capoor** និងលោក **Varma** ក្នុងឆ្នាំ ១៩៤៨ ។

ខ-សត្វល្អិតសំខាន់ៗ

ចំពោះដំណាំននោងសត្វល្អិតបំផ្លាញមានច្រើនលក្ខណៈដូចជា៖ បំផ្លាញផ្លែស្លឹកមានដង្កូវម្ជូរស្លឹក ដង្កូវកាត់ស្លឹក និងពពួកជញ្ជក់ស្លឹកដូចជា: មមាចខៀវ និង មមាចខ្នងស ។

-ដង្កូវចោះផ្លែឈ្មោះ **Fruit borer** វាចោះចូលទៅក្នុងផ្លែ ធ្វើឲ្យផ្លែមិនអាចលូតលាស់បាន

-រុយលើដំណាំហូបផ្លែឈ្មោះ **Dacus flies** រុយប្រភេទនេះបំផ្លាញផ្លែ ដោយចាក់បញ្ចូលពងទៅក្នុងផ្លែ ននោង ត្រសក់ល្ពៅ ត្រឡាច ម្រះ មីឡុង និង ផ្លែឈើមួយចំនួនទៀត បន្ទាប់មកដង្កូវរុយញាស់មកស៊ីបំផ្លាញផ្លែឈើទាំងនោះ ធ្វើឲ្យស្អុយ

រលួយជ្រុះមកដី ។

-ស្រឹងជញ្ជក់ផ្លែ មានស្រឹងខៀវ **Green bug** ស្រឹងខ្មៅ **Black bug** ជញ្ជក់ផ្លែ ធ្វើឲ្យផ្លែក្រិនលែងលូតលាស់បាន ចំពោះការផលិតពូជវិញធ្វើឲ្យគ្រាប់ពូជខ្សោយដំណុះ ឬគ្មានដំណុះបណ្ដាលមកពីសារធាតុបំរុងក្នុងគ្រាប់ពូជរងការបំផ្លាញ ។

-ដង្កូវមូរស្លឹកឈ្មោះ **Luffa Leaf roller** តែងតែស៊ីស្លឹកខ្ចី ឬ ត្រួយ ហើយធ្វើឲ្យស្លឹករមូរជាប់គ្នាជាជំរករស់នៅពេលថ្ងៃ ។

-ដង្កូវកាត់ដើម ស្លឹក **Cut worm**វាតែងតែកាត់ដើមននោងនៅតូចៗទើបលូតលាស់ដំបូង និងកាត់ស្លឹកពេលកំពុងលូតលាស់ពេញលក្ខណៈ ។

-ពពួកស៊ីជាលិកាក្នុងស្លឹក **Leaf miners** ពួកដង្កូវនេះកើតចេញពីរុយតូចៗ ពងដាក់លើស្លឹកពី៦-៨ម៉ោងក្រោយមកវាញាស់ ហើយស៊ីនៅក្នុងផ្ទៃស្លឹក ។ ស្នាមបំផ្លាញរបស់វាដូចជាគំនូសផែនទីវាចូលចិត្តបំផ្លាញននោង សណ្ដែកកួរ ត្រឡាចត្រសក់ ល្ពៅ និង ប៉េងប៉ោះ ។

-ពពួកជញ្ជក់ស្លឹកដូចជា៖ មមាចខៀវ **(Green Hopper)** មមាចខ្នងស **(White Back Hopper)** វាជញ្ជក់ធ្វើឲ្យបន្ថយការលូតលាស់ និងជាភ្នាក់ងារចម្លងជម្ងឺវីរុស ។

គ-វិធានការការពារនិងកំចាត់

វិធានការការពារ និង កំចាត់មានច្រើនវិធីដូចជា៖

-វិធីសាស្រ្តដាំដុះ: បំពក់ផ្សែងឲ្យហុយក្រោមផ្ទើរពី ១-២ ដង/អាទិត្យ

-ដាំដុះឲ្យមានចន្លោះគុម្ពសមស្រប ការពារកុំអោយដើមវាគរលើច្រើន ព្រមទាំងពូជមិនប្រកាន់រដូវ អាយុកាលល្មមលាស់ខ្លី ។

-ដកចោលចំពោះដើមដែលកើតជម្ងឺ ជាពិសេសជម្ងឺផ្សិត និង ជម្ងឺវីរុស

-បាញ់ថ្នាំ **Diazinon** មួយអាទិត្យម្តង ទៅតាមកំរិតបំផ្លាញ ។

## ៥-ការប្រមូលផល

ការប្រមូលផលធ្វើឡើងក្រោយពីដាំដុះរយៈពេល ៥០-៦០ថ្ងៃ (ចំពោះពូជស្រាល) ចំពោះពូជក្នុងស្រុកមានរយៈពេល ១០០-១៥០ថ្ងៃ ម្យ៉ាងទៀតគេអាចបេះផ្លែននោងនៅខ្ចី ក្រោយពីវាចេញផ្កាបានចំនួន១០-១២ថ្ងៃ ក្នុងរយៈពេលនោះផ្លែននោងនៅមានសារធាតុចិញ្ចឹមខ្ពស់ ហើយមានរសជាតិឆ្ងាញ់ ។ គេបេះដោយប្រើកូនកាំបិតឬកន្ត្រៃកាត់ផ្តាច់ ហាមបេះដោយទាញផ្តាច់ពីដើម ។ ម្យ៉ាងទៀតបើយើងទុកឲ្យផ្លែននោងធំ ឬ យូរថ្ងៃនោះ

យើងមិនអាចបរិភោគបាន ដោយមកពីជាតិសរសៃរនៅក្នុងផ្លែ និងគ្រាប់រឹងស្វិតអស់គុណភាព ។

ចំពោះការប្រមូលពូជ គេអាចបេះផ្លែទុកពូជក្រោយពីដាំរយៈពេលពី៩០-១២០ថ្ងៃ ។ ការដាំផលិតពូជ និងផលិតបន្លែស្រស់មានភាពខុសប្លែកពីគ្នា ។ ចំពោះការប្រមូលផលពូជ គេប្រមូលបានតែចំនួន៥-៦លើកប៉ុណ្ណោះ ដើមនឹងចុះខ្សោយលែងមានផ្លែ ។ ប៉ុន្តែចំពោះការប្រមូលផលជាបន្លែស្រស់វិញគេអាចធ្វើឡើងពី១៥-២០លើកជាមធ្យម ។ គេបេះននោងពូជនៅពេលវាទុំ ហើយស្ងួតសំបក ១០០% បន្ទាប់មកគេបំបែកចុងផ្លែ ផ្នែកខាងក្រោម ហើយរលាក់យកគ្រាប់មកដាក់ហាលថ្ងៃពី២-៣ថ្ងៃ ទើបយកទៅទុកដាក់បាន។ លក្ខណៈពិសេសរបស់គ្រាប់ននោងក្នុង១ផ្លែមានចំនួនពី ២៥២-៤៩៤ គ្រាប់ជាមធ្យម (គ្រាប់មានលក្ខណៈគត់គួរ) ។



# ដំណាំត្រកួន



## ១-ស្ថានភាពទូទៅ

ត្រកួនជាដំណាំមួយមានប្រជាប្រិយ៍ភាព នៅភូមិភាគអាស៊ីអាគ្នេយ៍ ដូចជានៅប្រទេសចិន ហុងកុង, តៃវ៉ាន់ និង Southern China ក្រោយមកនៅចុងសតវត្សទី១៥ វាបានរីកពេញទូទាំងទ្វីបអាស៊ី ។ តាមការបែងចែករបស់លោក Poiret ក្នុងឆ្នាំ ១៨១៤ ដោយសំអាងទៅលើពណ៌របស់ផ្កាមាន២យ៉ាងគឺ៖

-ប្រភេទទី១: ពណ៌របស់ផ្កាមានពណ៌ស្វាយស្រាល ដើម

មានពណ៌បៃតងចាស់ ឬពណ៌ឈាមជ្រូកស្លឹកតូចល្អិតគេហៅថា (Read Kang Kong) ឬត្រកួនព្រៃ ។



-ប្រភេទទី២: ពណ៌របស់ផ្កាស ដើមពណ៌បៃតងខ្ចីថ្លោស ស្លឹកធំវែង គេហៅថាត្រកួនស(White Kang Kong)ឬត្រកួនចិន ។



## ២- បច្ចេកទេសដាំដុះ

ក-<u>រដូវកាលដាំដុះ</u> អាចដាំបានពេញមួយឆ្នាំ និងគ្រប់រដូវ

ខ-<u>ការជ្រើសរើសពូជ</u>

-គ្រាប់ធំល្អមានអត្រាដំណុះលើសពី៨៥%

-គ្រាប់ពូជដែលមានដើមថ្លោសល្អ មានថ្នាំងរង្វើលដុះឈរត្រង់ ហើយមានខ្នែង

-គ្មានជម្ងឺ និងសត្វល្អិតបំផ្លាញ ហើយជាគ្រាប់ពូជថ្មីសុទ្ធល្អ

-មុនពេលដាំ ត្រូវយកគ្រាប់ពូជទាំងនោះទៅហាលឲ្យស្ងួតរយៈពេល១-២ថ្ងៃ បន្ថែមទៀត

-បន្ទាប់មកយកគ្រាប់ពូជទៅត្រាំទឹក រយៈពេល១យប់ដើម្បីឲ្យគ្រាប់ឆាប់ដុះពន្លក

គ-<u>ការជ្រើសរើស និង រៀបចំដី</u>

-អាចដាំដុះបានលើប្រភេទដីមាត់ទន្លេ មាត់ស្ទឹង បឹងបួរព្រែក ដីទូលមិនលិចទឹក ដីដែលមាន PH ៥,៣-៦

-ការរៀបចំដីសម្រាប់ដាំលើរង ភ្ជួរហាលដីចោលឲ្យស្ងួតរយៈពេលពី ៧-១០ថ្ងៃ ប្រមូលយកស្មៅចេញបន្ទាប់មកលើករងឲ្យបានកំពស់២០-២៥ស.ម ទទឹងរង១០០-១២០ស.ម ដោយយកជីធម្មជាតិលាមកសត្វគ្រប់ប្រភេទបាចលើរង ឲ្យបាន២-៣

បង្គីសម្រាប់ថ្នាល១០ម² ហើយយកជី១៥-១៥-១៥ ចំនួន ១០០-១៥០ក្រាម ហើយរាស់លប់ទៅក្នុងដី ។ ១ហិកតាដាក់ជីធម្មជាតិ ១០-១៥តោន និងជី១៥-១៥-១៥ ចំនួន១០០-១៥០គ.ក្រ ។

-ការរៀបចំដីសំរាប់ត្រកួនទឹក (ត្រកួនស្រែ) ត្រូវភ្ជួររាស់ដីស្រែមានទឹកសើមៗមានភ្លឺព័ទ្ធជុំវិញ ។ មុននឹងភ្ជួររាស់ត្រូវយកជីធម្មជាតិ និងជី១៥-១៥-១៥ ទៅបាចជាមុន បន្ទាប់មកភ្ជួរលប់ទៅក្នុងដី ហើយរាស់បំបែកដីឲ្យល្អិតប្រមូលយកស្មៅចេញឲ្យស្អាត ។

ឃ-<u>ការដាំដុះ</u>



-ការដាំដោយគ្រាប់: ដំបូងត្រូវឆូតជាចង្អូរៗទទឹងរងចន្លោះចង្អូរ១៥ស.ម ជំរៅ ៣-៤ស.ម បន្ទាប់មកយកគ្រាប់ពូជទៅពោយតាមចង្អូរនោះចំងាយពីគ្រាប់មួយទៅមួយ១-២ស.ម រួចលប់ដីពីលើបន្តិចៗ និង បាចកំណាត់ចំបើងខ្លីៗពីលើឲ្យជិត

ស្រោចទឹកឲ្យជោគរាល់ថ្ងៃ១ថ្ងៃ២ដង រយៈពេល៤-៥ថ្ងៃត្រកួននិងដុះចេញផុតពីដី ។

-ការដាំដោយទង: គឺត្រូវយកទងត្រកួនដែលបានរក្សាទុក២-៣ថ្ងៃ រួចយកទៅស្ទូងក្នុងស្រែដីសើម ដោយប្រើចន្លោះជួរ៤០ស.ម ចន្លោះគុម្ព៣០ស.ម ដាំ១គុម្ព១ទង របៀបស្ទូងត្រូវកប់ថ្នាំងមួយចូលទៅក្នុងដី ក្រោយពីស្ទូងបាន៥-៧ថ្ងៃ ត្រូវបញ្ចូលទឹកអោយលិចរយៈពេល១យប់ បន្ទាប់មកបញ្ចេញទឹកចោល១ភាគ ទុក១ភាគត្រាំគល់ត្រកួន ធ្វើរបៀបនេះត្រកួនអាចដុះលូតលាស់លឿនឆាប់បានប្រមូលផល ។



ង-*__ការជ្រុំជ្រោយដី និងដកស្មៅ__*

-ការដាំដុះដោយគ្រាប់៖ គេត្រូវជ្រុំជ្រោយដីនិងដកស្មៅក្រោយពីដាំបានរយៈពេល១០ថ្ងៃ គឺដកយកស្មៅចេញហើយជ្រុំ

ដីឲ្យផុសពេញលើរង ព្រមទាំងលប់គល់បន្តិចៗ ធ្វើរបៀបនេះត្រកួនមានលទ្ធភាពដុះលូតលាស់កាន់តែលឿន ។

-ការដាំដុះដោយទង: មិនត្រូវជ្រុំជ្រោយដីឡើយ ប៉ុន្តែគេត្រូវព្យាយាមដកស្មៅចេញពីស្រែ ត្រកួនរយ:ពេល១០-១៥ថ្ងៃក្រោយពីស្ទូង ហើយបន្តការដករហូតដល់ត្រកួនដុះលូតលាស់ជិតដី គ្របពីលើស្មៅ ។

**ច-<u>ការស្រោចទឹក</u>**

-ស្រោចទឹក២ដង ក្នុង១ថ្ងៃ (ព្រឹក និងល្ងាច) ស្រោចឲ្យជោគព្រោះត្រកួនត្រូវការទឹកច្រើន ការប្រើទឹកមិនគ្រប់គ្រាន់នាំឲ្យដើមត្រកួនក្រិន រឹង ចាស់ មិនសូវលូតលាស់ ។

-ត្រូវស្រោចទឹកឲ្យបានទៀងទាត់ពេលវេលារៀងរាល់ថ្ងៃ

**ឆ-<u>ការដាក់ជី</u>**

-ដាក់ជីកំប៉ុស្ត ឬជីលាមកសត្វ២-៣គក្រក្នុង១ម$^2$ ឬ ជីអាចម៍មាន់, ជីអាចម៍ប្រចៀវ១គ.ក្រក្នុង១ម$^2$

-ដាក់ជីអ៊ុយរ៉េ២០-៣០ក្រាមក្នុង១០ម$^2$ លាយជាមួយទឹក២០លីត្រ រួចស្រោចលើរងត្រកួនក្នុងរយ:ពេល៧ថ្ងៃម្តង ។

**ជ-<u>ការដាក់ជី និង ជ្រោយដីក្រោយពីកាត់លើកទី១</u>**

-ដាក់ជីកំប៉ុស្ត ឬជីលាមកសត្វ ២-៣គ.ក្រ ក្នុង១ម$^2$ មុនពេលកាត់៧ថ្ងៃ ឬក្រោយពេលកាត់ហើយភ្លាម

-ជ្រោយដីភ្លាមក្រោយពីកាត់រួច ដើម្បីឲ្យវាឆាប់លាស់ត្រួយថ្មី

-បន្ទាប់ពីត្រកួនចេញត្រួយ យើងអាចប្រើជីអ៊ុយរ៉េ ២០-៣០ក្រាម ក្នុង១០ម² លាយទឹក២០លីត្រស្រោចលើវា

-រយៈពេល ១៥-២០ថ្ងៃក្រោយ យើងអាចកាត់វាបានជាលើកទី២ ។

## ៣-ជម្ងឺ និង សត្វល្អិត

ចំពោះដំណាំត្រកួន ជម្ងឺ និង សត្វល្អិតចង្រៃពុំសូវចោទជាបញ្ហាអ្វីឡើយ ។ ដូចនេះត្រកួនវាជាដំណាំមួយប្រភេទ ដែលងាយដាំដុះបំផុតនៅក្នុងប្រទេសកម្ពុជាយើង ។

## ៤-ការប្រមូលផល

គេអាចប្រមូលផលបានក្រោយពីដាំរយៈពេល ២៨-៣៥ថ្ងៃ យើងអាចដកវាទាំងឫស ឬកាត់វាត្រឹមគល់ក៏បាន ការដែលយើងដកវាទាំងឫសនាំឲ្យយើងខាតបង់ថវិកាច្រើន ក្នុងការដាំដុះវាឡើងវិញ ។ ចំពោះការកាត់ដើមយើងត្រូវកាត់វាអោយសល់កំពស់ពីដីប្រវែង២-៣ស.ម និង អាចឲ្យត្រកួនដុះខ្នែងថ្មីម៉្យាងទៀតជាការងាយស្រួលក្នុងការជ្រោយដី នៅពេលកាត់ហើយភ្លាម។ ក្នុងការដាំគ្រាប់ម្តងៗ យើងអាចប្រមូលផលបានពី ៣-៥សារ ឬច្រើនជាងនេះ ។

ចំពោះការដាំជាត្រកួនស្រែ គេអាចច្រូតកាត់ទងត្រកួនរៀងរាល់សប្ដាហ៍ អាស្រ័យទៅលើការថែទាំ ជាពិសេសគឺការបញ្ចូលទឹក និងបន្ថែមជីអាសូត (N) ។



# ដំណាំស្ពៃចង្កឹះ

## ១-ស្ថានភាពទូទៅ



ស្ពៃចង្កឹះជាប្រភេទបន្លែយកស្លឹក កសិករយើងនិយមចូលចិត្តដាំដុះព្រោះបន្លែប្រភេទនេះងាយស្រួលក្នុងការយកមកកែច្នៃ សម្រាប់ធ្វើជាម្ហូបអាហារនៅតាមគ្រួសារ និងសម្រាប់ធ្វើការលក់ដូរនៅតាមទីផ្សារទៀតផង ។ ស្ពៃចង្កឹះសំបូរទៅដោយជីវជាតិជាច្រើនដូចជា: ប្រូតេអ៊ីន វិតាមីន A វិតាមីន B វិតាមីន C ព្រមទាំងសារធាតុរ៉ែផ្សេងៗជាច្រើន ។

ក-<u>រដូវកាលដាំដុះ</u>

វាជាប្រភេទដំណាំមិនប្រកាន់រដូវ (អាចដាំបានពេញមួយឆ្នាំ ) រដូវកាលសមស្របចាប់ពីចុងខែតុលា ដល់ ខែមករា(រដូវរងារ) ។ ចំណែកនៅរដូវក្តៅវិញការដាំដុះជួបសត្វល្អិតបំផ្លាញច្រើន ។

ខ-ការជ្រើសរើសពូជ

-ពូជមានប្រភពច្បាស់លាស់

-ពូជសុទ្ធ គ្មានជម្ងឺ សត្វល្អិតបំផ្លាញ

-ពូជធន់ទ្រាំជម្ងឺ និង សត្វល្អិត

-ពូជផ្តល់ទិន្នខ្ពស់ អាយុកាលល្មមលាស់ខ្លី (តម្រូវការទីផ្សារ)

-មានដំណុះពី ៨៥-៩០%

-គេប្រើគ្រាប់ពូជចំនួន២,៥គ.ក្រ សំរាប់ស្ទូងនិង៤,៥គ.ក្រ សម្រាប់សាបផ្ទាល់ ។

គ-ការជ្រើសរើស និង រៀបចំដី

គ.១-ការជ្រើសរើសដី: ដីទួលមិនលិចទឹកក្នុងភូមិ ដីមាត់ទន្លេ មាត់ស្ទឹង ដីល្បាប់ ដីល្បាយខ្សាច់ ដាំបានលើដីគ្រប់ប្រភេទ ដីមាន PH ៥-៧ ។

គ.២-ការរៀបចំដី

-កាប់ ឬ ភ្ជួររាស់ដីឲ្យបានច្រើនដង (៣ដង )

-រាស់បំបែកដីឲ្យម៉ត់ល្អ ប្រមូលយកស្មៅចេញឲ្យបានស្អាត

-ហាលដីឲ្យស្ងួត ដើម្បីឲ្យដីជ្រាបទឹកបានល្អ និងដើម្បីសម្លាប់សត្វល្អិត ជម្ងឺផ្សេងៗ

-លើករងដែលមានៈ ទទឹង ១០០ស.ម ,បណ្ដោយពី១០-១៥ម , កំពស់រងពី ២០-២៥ស.ម

**ឃ-ការដាំដុះ**

ឃ.១-ការសាបកូន

-យកជីកំប៉ុស្ដ ឬ ជីលាមកសត្វពី ៤-៥បង្គី មកដាក់លើផ្ទៃរង១៥ម២

-ជី១៥-១៥-១៥ ឬ ជីDAP ចំនួន១៥០-២០០ក្រាម មកដាក់លើផ្ទៃរង១៥ម២

-យកថ្នាំFuradan 3Hមករោយពីលើចំនួន១០ក្រាម ផ្ទៃរង១៥ម២ ការពារកុំឲ្យសត្វល្អិតស៊ីបំផ្លាញគ្រាប់ ឬដំណុះថ្មីៗ

-ស្រោចទឹកឹឲ្យជោគលើថ្នាល

-បន្ទាប់មកយកគ្រាប់ពូជទៅលាយថ្នាំZineb ឬOrthocide បន្តិចៗ ទើបយកទៅសាប

-យកកំណាត់ចំបើងស្ងួតមករោយពីលើរង រួចស្រោចទឹកឲ្យ ជោគ។



ឃ.២-ការស្ទូងកូន

-ស្រោចទឹកឲ្យជោគលើរង មុនពេលស្ទូង

-ដកកូនស្ពៃណាដែលថ្លោសល្អយកមកស្ទូង

-កូនស្ពៃមានអាយុពី១៨-២០ថ្ងៃ និងមានសន្លឹកពី៣-៤ សន្លឹក ហើយមុនដកត្រូវផ្អាកការស្រោចទឹកចំនួន២ថ្ងៃសិន បន្ទាប់មកស្រោចទឹកឲ្យជោគ ទើបដកយកទៅស្ទូង ។

-កូនស្ពៃត្រូវស្ទូង នៅពេលល្ងាចមេឃត្រជាក់ស្ទូង១ដើម ក្នុង១គុម្ព, ចន្លោះ១៥ស.ម x ១៥ស.ម ។



ង-ការជ្រុំជ្រោយដី និង កំចាត់ស្មៅ

ការជ្រុំជ្រោយដីក្រោយពីស្ទូងបានរយៈពេល៧-១០ថ្ងៃ គឺធ្វើឲ្យដីធូរជ្រាបទឹកល្អ មានខ្យល់គ្រប់គ្រាន់ សម្រួលដល់ការដុះលូតលាស់ ព្រមទាំងបន្ថយការដុះស្មៅ ។ មុនពេលជ្រុំជ្រោយដីឡើងវិញត្រូវដកស្មៅចេញ ផ្អាកការស្រោចទឹក១-២ថ្ងៃ ទើបអាចជ្រុំបានដោយប្រើកូនចបកាប់បំបែកដីមុខលើ និង ហាលដី

នោះ១ថ្ងៃឲ្យស្ងួត និងឲ្យស្មៅចង្រៃលែងលូតលាស់ ។ គេអាចដកស្មៅលើកទី២ នៅពេលស្ពៃមានអាយុ ២៥ថ្ងៃក្រោយស្ទូង តែហាមជ្រុំជ្រោយដី ។

ច-<u>ការស្រោចស្រព</u>

គេត្រូវស្រោចទឹកព្រឹកល្ងាច ចំពោះរដូវប្រាំង តែចំពោះរដូវវស្សាវិញ គេត្រូវស្រោចលាងស្លឹកស្ពៃក្រោយមានភ្លៀង ។

**ឆ-<u>ការដាក់ជី:</u>** គេចែកការដាក់ជីជា៤តំណាក់កាលគឺ៖

-ដំណាក់កាលមុនពេលសាបឬស្ទូង: គេប្រើជី១៥-១៥-១៥ ចំនួន១០០គ.ក្រក្នុង១ហិកតា ឬ១០០ក្រាម លើផ្ទៃដី១០ម$^2$ ដោយលាយជាមួយជីកំប៉ុស្ត ឬជីលាមកសត្វចំនួន១០-១៥គ.ក្រ ហើយរាស់លប់ទៅក្នុដី ។

-ការស្រោចបំប៉នលើកទី១: ជីអ៊ុយរ៉េចំនួន៤០-៥០គ.ក្រ ក្នុង១ហិកតា ដោយលាយទឹកស្រោច ។ របៀបប្រើគឺ១ស្លាបព្រាបាយលាយទឹក១ធុង១៨លីត្រ ស្រោចលើផ្ទៃដី១០ម$^2$ ហើយត្រូវស្រោចទឹកលាងតាមក្រោយឲ្យជោគ ការពារជីដក់នៅក្នុងកំពូលកូនស្ពៃ ក្រោយពី សាបបាន ៨-១០ថ្ងៃ ឬ ក្រោយពីស្ទូង ៥-៧ថ្ងៃ ។

-ការបំប៉នលើកទី២: គឺក្រោយសាបរយៈពេល១៥-១៨ថ្ងៃ ឬក្រោយស្ទូង១០ថ្ងៃ ដាក់ជី១៥-១៥-១៥ ចំនួន១០០គ.ក្រ

ក្នុង១ហិកតា ឬ១០០ក្រាម លើផ្ទៃដី១០ម² ត្រូវរោយតាមចន្លោះគុម្ព ហើយស្រោចទឹកឲ្យជោគ។

-ការស្រោចបំប៉នលើកទី៣: គឺដាក់ប្រភេទជីអ៊ុយរ៉េចំនួន៦០-៧០គ.ក្រ ក្នុង១ហិកតា ឬ២ស្លាបព្រាបាយលាយជាមួយទឹក១៨លីត្រ ស្រោចលើផ្ទៃដី១០ម² ក្រោយពីសាបបានអាយុ២៥-៣០ថ្ងៃ ឬក្រោយស្ទូង២០ថ្ងៃ បន្ទាប់មកស្រោចទឹកលាងតាមក្រោយឲ្យជោគ ។

## ២-ជម្ងឺ និង សត្វល្អិត

ក-<u>ជម្ងឺ:</u> ដំណាំស្ពៃចង្កឹះតែងតែជួបជម្ងឺសំខាន់ៗ ៣គឺ:

-តំណាក់កាលសំណាប: កើតជម្ងឺផ្សិតរលួយគល់ ជម្ងឺនេះបណ្តាលមកពីសំណើម សីតុណ្ហភាព និងសំណើមបរិយាកាសវាតែងតែកើតលើកូនស្ពៃមានអាយុពី៥-១០ថ្ងៃ ក្រោយពីដុះធ្វើអោយគល់របស់កូនស្ពៃស្វិតរលួយហើយដាច់ក្បែរៗដី វាជាប្រភេទជម្ងឺផ្សិត ឈ្មោះ Damping off ។

-ដំណាក់កាលស្ពៃកំពុងលូតលាស់: ធ្វើឲ្យស្លឹកស្ពៃរហែកជាជំរៀកៗ ហើយស្លោកស្ងួតពណ៌ស វាកើតឡើងក្នុងលក្ខខណ្ឌក្តៅសើម ហៅថា White spot ។

-ដំណាក់កាលលូតលាស់: ធ្វើឲ្យស្លឹកស្ពៃរលាកជាំពេញផ្ទៃស្លឹក ដូចរលាកទឹកក្តៅ វាកើតលើប្រភេទស្ពៃជាច្រើន ជម្ងឺនេះ

ភាគច្រើនបង្កឡើងដោយលក្ខខណ្ឌដូចជា គ្រាប់ពូជមានជម្ងឺពីរដូវមុន ស្មៅលូតលាស់ច្រើន (ចម្លងពីស្មៅ) អាកាសធាតុប្រែប្រួលក្ដៅសើម ។

ខ-<u>សត្វល្អិតសំខាន់ៗ</u>

-ដង្កូវយោលទោងៈ ដង្កូវប្រភេទនេះមានមាឌតូចៗពណ៌ខៀវដូចស្លឹកស្ពៃ ហើយស៊ីបកជាលិកាស្លឹកផ្នែកខាងក្រោម ការបំផ្លាញមានលក្ខណៈជាក្រុមៗ ការបំផ្លាញខ្លាំងនៅរដូវក្ដៅ ជាពិសេសពីខែវិច្ឆិកាដល់ខែមេសា ចំណែករដូវវស្សាវាពុំមានលក្ខណៈធ្ងន់ធ្ងរឡើយដោយសារទឹកភ្លៀង ។ ទឹកភ្លៀងមានឥទ្ធិពលធ្វើឲ្យការបង្កកំណើតមានកំរិតទាប ។




-ដង្កូវហ្វូងៈ ដង្កូវប្រភេទនេះកើតពេញមួយឆ្នាំ ការបំផ្លាញរបស់វាគឺស៊ីជាក្រុមៗកាត់ស្លឹកខ្ទីៗ ឬ ចូលទៅជ្រកស៊ីក្នុងបណ្ដូលស្ពៃ វាមានមាឌធំហើយវែងៗ មេអំបៅរបស់វាចូលចិត្តជ្រកក្នុងស្មៅក្រោមស្លឹកស្ពៃ និងពងដាក់លើស្លឹកស្ពៃផ្នែកខាង

ក្រោមស្លឹកជាសំបុកៗ ខ្លះមានស្បែគំរបការពារពីលើពង ។ វាអាចមានអាយុពី ៤០-៤៣ថ្ងៃ ហើយដឹកឌឿរបស់វាលាក់ខ្លួននៅក្នុងដីលើថ្នាលដំណាំ ។

-សត្វទាកគួរៈ សត្វប្រភេទនេះមិនមែនជាដង្កូវឡើយ គឺវាមានស្លាបអាចលោត ឬហោះហើរបាន វាមានមាឌតូចៗលក្ខណៈជាហ្វូងៗ ការបំផ្លាញច្រើននៅរដូវក្តៅ ជាពិសេសដីស្ងួតមានកំដៅ វាអាចកកើតបានរហ័ស ។ គេចែកការបំផ្លាញរបស់វាជា២បែបគឺ៖

➤កូនទើបនិងញាស់៖ វាស៊ីឫសស្ពៃនៅក្នុងដី ធ្វើឲ្យឫសស្ពៃពុក បន្ថយការលូតលាស់យ៉ាងខ្លាំង ព្រោះមេចំណាស់របស់វា ពងដាក់ក្នុងដីក្បែរគល់ស្ពៃ ហើយញាស់ស៊ីឫសស្ពៃតែម្តង ។

➤មេចំណាស់៖ ក្រោយពីវាញាស់មានស្លាបអាចហើរបាន វាហើរទៅទុំលើស្លឹកស្ពៃ ហើយស៊ីទំលុះស្លឹកស្ពៃរទុះៗ ដូចស្បៃ ធ្វើឲ្យស្ពៃរញមពេលថ្ងៃ បន្ថយការលូតលាស់យ៉ាងខ្លាំង ហើយស្លឹកស្ពៃមិនអាចលក់បានតំលៃថ្លៃឡើយគឺក្រិន។

គ-វិធានការការពារ

ការការពារជម្ងឺ និង សត្វល្អិត គេអាចអនុវត្តបានច្រើនវិធីសាស្រ្តដូចជា៖

គ.១-ការការពារជម្ងឺៈ អាចអនុវត្តបានច្រើនវិធីសាស្រ្ត

ដូចជាការកំចាត់ស្មៅ ភ្ជួររាស់ហាលដីឲ្យស្ងួត ដាំដោយគ្រាប់ចំបើង ជ្រើសរើសពូជធន់ ជ្រើសរើសរដូវដាំដុះ។ និងអាចប្រើវិធានការ គីមីដូចជាប្រភេទថ្នាំZineb,Maneb,Mancozeb,Captan, Cooperhydroxide ដែលអាចយកមកលាយទឹកបាញ់ ក្នុងកំរិត ១៥-២០ក្រាម លាយទឹក១៥-១៨លីត្របាញ់ឲ្យជោគបន្ថយការ ស្រោចទឹក និងស្រោចដី ជាពិសេសលើជម្ងឺផ្សិត ។

គ.២-ការការពារ និងកំចាត់សត្វល្អិតៈ អាចអនុវត្តបាន ច្រើនវិធីសាស្ត្រដូចជាការជ្រើសរើសរដូវដាំដុះ ការជ្រើសរើស ពូជ ការរៀបចំដីឲ្យបានស្អាតកំចាត់ស្មៅ។ ចំពោះវិធានការគីមី ប្រភេទសត្វល្អិតទាំងនេះ មានតែដង្កូវឃោលទោងមួយដែល ពិបាកកំចាត់ ព្រោះវាមានកំរិតធន់ទ្រាំទៅនិងថ្នាំគីមីជាច្រើន ប្រភេទ ។ ការកំចាត់សត្វល្អិតអោយមានប្រសិទ្ធភាព គឺត្រូវ ពិនិត្យមើលវត្តមានសត្វល្អិតជាប្រចាំ ហើយត្រូវយល់ដឹងឲ្យបាន ច្បាស់អំពីសត្វល្អិតនិមួយៗជាពិសេសគឺ មេអំបៅរបស់វានៅ ពេលល្ងាចថ្ងៃលិច ប្រសិនបើមានវត្តមានមេអំបៅ២-៣ថ្ងៃ ក្រោយមកលេចចេញវត្តមានការបំផ្លាញជាបន្តបន្ទាប់ ។

### ៣-ការប្រមូលផល

ការប្រមូលផល ធ្វើឡើងតាមរបៀបផ្សេងៗគ្នា គេអាច ដកទាំងឫស ឬកាត់យកតែដើម គឺអាស្រ័យទៅតាមតម្រូវការ

ទីផ្សារ ។ ប៉ុន្តែមុននិងកាត់ ឬដកស្ពៃមិនត្រូវស្រោចទឹកឡើយ ទុកឲ្យស្លឹកស្ពៃស្ងួតការពារភាពជាំទឹក ឬកកិតស្ពៃនេះអាចដក ឬ កាត់បានក្រោយពីសាបរយៈពេល៣០-៣៥ថ្ងៃ ឬក្រោយពីស្ទូង ២៨-៣០ថ្ងៃ ។

នៅពេលបច្ចុប្បន្ននេះ ដោយសារអាហារជាច្រើនត្រូវការស្ពៃមានដើម ស្លឹកតូចៗ គេអាចកាត់ស្ពៃក្រោយពីសាបបាន១៨-២០ថ្ងៃ ។ ទិន្នផលមធ្យមចន្លោះពី ១០-១៥តោន ក្នុង១ហិកតា វាអាស្រ័យទៅលើការដាំដុះការថែទាំ និងប្រភេទពូជ។



# ដំណាំល្ពៅ

## ១-ស្ថានភាពទូទៅ



ល្ពៅជាប្រភេទដំណាំបន្លែ ម៉្យាងដែលដុះលូតលាស់ នៅលើពិភពលោកជាច្រើនពាន់ឆ្នាំកន្លងមកហើយ ម៉្យាងទៀតវាក៏ត្រូវបានគេប្រើប្រាស់ ជាបន្លែដ៏មានប្រជាប្រិយ៍ភាព នៅក្នុងជីវភាពប្រចាំថ្ងៃ ។ ដំណាំនេះមានប្រភពកំណើត នៅភូមិភាគកណ្តាលនៃប្រទេសម៉ិចស៊ិច (ទ្វីបអាមេរិក) ហើយមានចំនួន២៥ប្រភេទក្នុងអំបូរល្ពៅ ព្រមទាំងត្រូវបានគេដាំ និងប្រើប្រាស់មកទល់ពេលនេះទូទាំងពិភពលោក ។ គេបែងចែកល្ពៅជា២ប្រភេទគឺល្ពៅផ្លែទ្រមៀច ល្ពៅផ្លែវែង ឬល្ពៅទ្រូ។ គេអាចបរិភោគបានច្រើនផ្នែកដូចជា: ទងខ្ចី ផ្កាឈ្មោលនិងផ្លែ។

## ២-បច្ចេកទេសដាំផុះ

*ក-<u>រដូវកាលដាំផុះ</u>* គេអាចដាំបានពេញមួយឆ្នាំ និង គ្រប់រដូវ

-រដូវប្រាំង: ចាប់ពីខែវិច្ឆិកា ដល់ខែមករា និងខែកុម្ភៈ នៅតំបន់វាលទំនាប

-រដូវវស្សា: ចាប់ពីខែឧសភា ដល់ខែតុលា នៅតំបន់ខ្ពង់រាប

*ខ-<u>ការជ្រើសរើសពូជ</u>*

-ពូជមានប្រភពច្បាស់លាស់ (ពូជបង្កាត់ Hybrid $F_1$ ឬ ពូជក្នុងស្រុក)

-ពូជធន់និងជម្ងឺ សត្វល្អិត គ្រាប់ពូជត្រូវមានសុខភាពល្អ

-អាយុកាលលូតលាស់ខ្លី សមស្របតាមតំបន់ដាំផុះ និងតម្រូវការទីផ្សារ

-មានដំណុះចាប់ពី ៨៥-៩០%



*គ-ការរៀបចំដី*

ល្ពៅអាចឆ្លើយតបទៅនឹងដីស្ទើរគ្រប់ប្រភេទ ប៉ុន្តែដីដែលមានជីជាតិតិច ធ្វើឲ្យល្ពៅឆាប់អស់ផ្លែហើយងាប់ដើម។ ប្រភេទដីដែលដាំល្អគឺ ដីល្បប់ល្បាយខ្សាច់ ដីក្រហម ឬដីខ្មៅ ចំពោះដីដែលមិនជ្រាបទឹកល្អ មិនអាចធ្វើឲ្យល្ពៅទទួលបានទិន្នផលខ្ពស់ឡើយ ម៉្យាងទៀតមិនត្រូវដាំល្ពៅក្រោយពីដាំត្រសក់ ឪឡឹក ត្រឡាច PH សមស្របពី៦,៥-៧,៥ ។ ដើម្បីឲ្យការដាំដុះមានលក្ខណៈងាយស្រួលត្រូវភ្ជួរហាលដីឲ្យបានច្រើនសារ ហាលដីឲ្យស្ងួតយូរថ្ងៃរាស់បំបែកដីឲ្យល្អិត ហើយលើករងដែលមានទទឹងរង១៨០ស.ម, កំពស់រង២៥-៣០ស.ម ពង្រាបរងឲ្យស្មើ ហើយកាប់រណ្តៅចំកណ្តាលរងជំរៅ២០សម ចម្ងាយរណ្តៅ ១២០ស.ម បន្ទាប់មកយកជីធម្មជាតិគ្រប់ប្រភេទមកដាក់បាតរណ្តៅឲ្យបានច្រើនហើយលប់ដីអោយជិត។

*ឃ-ការដាំដុះ*

មុននឹងដាំត្រូវយកគ្រាប់ពូជមកសម្អាតជាមុន បន្ទាប់មកដាក់ហាលថ្ងៃឲ្យក្តៅ ដើម្បីដាស់ដំណេកគ្រាប់ពូជ ហើយដាក់ត្រាំទឹកមួយយប់ ក្រោយមកយកគ្រាប់ពូជទៅលាយជាមួយនិងថ្នាំសំលាប់ផ្សិតបន្តិចៗដូចជា:Mancozeb, Zineb ឬ Orthocide ។ គេអាចយកគ្រាប់ល្ពៅទៅដាំក្នុងរណ្តៅ ដែលបានកាប់ទុកជា

មុនចំនួន៣-៤គ្រាប់ ជម្រៅ២-៣ស.ម ។ ក្នុង១ហិកតាគេដាំចំនួន៤៥៦៥វណ្ដៅ ឬគុម្ពដោយប្រើគ្រាប់ពូជចំនួន៤-៥គ.ក្រ ។

*ង-ការជ្រុំជ្រោយដី*

ការជ្រុំជ្រោយដីមានប្រយោជន៍ធ្វើឲ្យដីធូរ បន្ថយការដុះស្មៅ បង្កឲ្យដីមានសំណើមគ្រប់គ្រាន់ ងាយស្រួលដល់ការដុះលូតលាស់ ព្រមទាំងបំបាត់ជំរកសត្វល្អិតផ្សេងៗ គេអាចជ្រុំដោយចបឲ្យផុសដី ហើយពូនគល់ឲ្យជិតពូនរងឡើងវិញក្រោយពីដាំរយៈពេល១៥-១៨ថ្ងៃ។ ពេលនោះគេអាចដករំលួសកូនចេញ ដោយទុកតែ ២-៣ដើមក្នុង១គុម្ព ។



*ច-ការប្រើប្រាស់ជី*

ដើម្បីឲ្យការលូតលាស់បានលឿន នឹងការបន្តពូជបានល្អ គេចែកការដាក់ជីចំនួន៣លើកក្នុង១វដ្ដជីវិតរបស់វា

-លើកទី១:ដាក់ជី១៥-១៥-១៥ចំនួន១០០គ.ក្រ/១ហិកតា

មកដាក់រោយជុំវិញគល់ចំងាយពី២០-៣០ស.ម មុនពេលជ្រុំជ្រោយដីលប់គល់ បន្ទាប់មកជ្រុំដីលប់និងពូនឡើង ។

-លើកទី២: យកជីអ៊ុយរ៉េមកលាយទឹកស្រោចឲ្យជោគជុំវិញគល់ ដោយប្រើ១៥-២០ក្រាមលាយទឹក១៨-២០លីត្រ ចំនួន២៥-៣០គ.ក្រក្នុង១ហិកតា ដាក់រយៈពេល២០ថ្ងៃក្រោយដាំ ។

-លើកទី៣: យកជី១៥-១៥-១៥ចំនួន១០០គ.ក/ហិកតា មកដាក់ក្បែរគុម្ពចម្ងាយ៣០ស.ម ហើយលប់ដីឲ្យជិតពីលើ ដើម្បីឲ្យល្ពៅបានផ្លែច្រើន ហើយផ្លែលូតលាស់បានល្អ រយៈពេល៤០ថ្ងៃក្រោយដាំ ។ បន្ទាប់គេអាចយកជីធម្មជាតិ មកដាក់ជុំវិញគល់ឲ្យច្រើន ហើយពូនលប់ឲ្យជិតគល់ល្ពៅ វាអាចរស់បានយូរ អាចយកទង ផ្កា ស្លឹក បរិភោគបន្តទៀត ។



*ឆ-ការស្រោចស្រព*

ល្ពៅជាប្រភេទដំណាំមួយ ដែលធន់ទ្រាំនឹងកង្វះទឹក ឬភាពរាំងស្ងួត ប៉ុន្តែកាលណាវគ្គចេញផ្កាសំណើមដីមិនគ្រប់គ្រាន់ធ្វើឲ្យថយចុះការបន្តពូជ បាត់បង់បរិមាណផ្លែយ៉ាងច្រើន ។ ការស្រោចស្រពចែកចេញជា៣វគ្គធំៗគឺ៖

-វគ្គលូតលាស់រហូតដល់ចេញផ្កាឈ្មោល: វាត្រូវការទឹកជាមធ្យមរយៈពេល៣-៤ថ្ងៃផ្តល់ទឹកម្តង ប៉ុន្តែសំណើមដីកំរិតទាបពី ៦០-៦៥% ។

-វគ្គចេញផ្កាដល់ផ្លែ: វគ្គនេះត្រូវផ្តល់ទឹកអោយបានគ្រប់គ្រាន់ដើម្បីឲ្យការបន្តពូជបានល្អ សំណើមដីពី៧០-៧៥% ហើយរក្សាសំណើមដីឲ្យបានថេរល្អ ។

-វគ្គផ្លែចាស់និងទុំ: ការផ្តល់ទឹកត្រូវថយចុះមកវិញម្តងបន្តិចៗ ហើយផ្អាកទាំងស្រុងពេលល្ពៅចាប់ផ្តើមប្រមូលផល ។

## ៣-ជម្ងឺ និង សត្វល្អិត

***ក.ជម្ងឺសំខាន់ៗ***ល្ពៅក៏ដូចជាដំណាំឯទៀតដែរតែងទទួលរងនូវជម្ងឺច្រើនប្រភេទដែលបង្កឡើងដោយក្រុមផ្សិតនិងវិរុស។

ក-១ ជម្ងឺបង្កឡើងដោយក្រុមផ្សិត

-ជំងឺរលួយគល់កូន (Damping off) ជម្ងឺប្រភេទនេះមេរោគភាគច្រើនរស់នៅជាមួយគ្រាប់ពូជ និងដី អាចឆ្លងនិងពង្រីកស្ព័ររបស់វានៅពេលកូនល្ពៅចាប់ផ្តើមដុះពន្លក ធ្វើឲ្យកូនល្ពៅ

តូចៗរលួយគល់ ហើយស្អិតក្នុងរយៈពេល៥-៧ថ្ងៃក្រោយដាំ ។ ក្នុងករណីជម្ងឺនេះកើតដែរ ប៉ុន្តែវាមិនរលួយអាចធ្វើឲ្យកូនល្ពៅលូតលាស់ខ្សោយ ហើយធ្វើឲ្យល្ពៅងាប់ក្នុងវគ្គចេញផ្លែ ។

-ជម្ងឺពពាលលឿងស្លឹក (Downy mildew) ជម្ងឺប្រភេទនេះតែងតែធ្វើឲ្យស្លឹកល្ពៅលឿងៗដុំៗ ហើយពពាលៗ ក្រោយមកធ្វើឲ្យស្លឹកស្ងួត វាតែងកើតឡើងនៅរដូវក្ដៅ ។ រោគសញ្ញាកើតចេញពីស្លឹកក្រោមក្បែរដីរីករាលដាលឡើងមកស្លឹកលើ ក្នុងវគ្គចេញផ្កា និងផ្លែ ។

-ជំងឺផ្សិតម្សៅលើស្លឹក (Powdery mildew) ដំបូងសង្កេតឃើញចំណុចម្សៅសៗ ជាដំណក់ៗនៅលើស្លឹករយៈពេល២-៣ថ្ងៃ បន្ទាប់មកចំណុចដុះរីកធំឡើងៗ ហើយដុះចេញនូវម្សៅសៗពេញផ្ទៃស្លឹក បន្ទាប់មកហុយឆ្លងពីចំការមួយទៅមួយធ្វើឲ្យស្លឹកស្ងួត អាចធ្វើឲ្យល្ពៅបន្ថយការបន្តពូជ និងផ្លែមិនរីកធំមិនទំុពេញលក្ខណៈបាន ។

-ជំងឺរលួយក្តិប (Fruit Rots) ជម្ងឺប្រភេទនេះតែងធ្វើឲ្យមានការរំខានដល់ការបន្តពូជ មេរោគផ្សិតធ្វើឲ្យប៉ះពាល់ដល់កេសញី និងឈ្មោល ធ្វើឲ្យផ្កាញីមិនអាចបន្តពូជបាន ក្តិបមិនរីកធំបន្ទាប់មកប្រែពណ៌ទៅជាពណ៌លឿងហើយរលួយ ភាគច្រើនកើតនៅរដូវវស្សាក្តៅសើម ។

✦វិធានការការពារ និងកំចាត់៖ ភ្ជួរហាលដីឲ្យស្ងួតយូរថ្ងៃមុននឹងដាំ កំចាត់ស្មៅឲ្យស្អាត ផ្លាស់ប្តូរមុខដំណាំ សម្អាតគ្រាប់ពូជមុនពេលដាំ ជ្រើសរើសពូជធន់ទ្រាំ ព្រមទាំងជ្រើសរើសរដូវដាំដុះ។ ជាពិសេសត្រូវយកគ្រាប់ពូជទៅលាយជាមួយថ្នាំសម្លាប់ផ្សិត មុននឹងដាំម៉្យាងទៀតយកថ្នាំសំលាប់ផ្សិតដូចជា Zineb, Mancozeb, Orthocide មកលាយជាមួយទឹកបាញ់ឲ្យជោគក្រោយពីកូនល្ពៅដុះពន្លក ព្រមទាំងបាញ់ទប់ទល់រយៈពេល ៥-៧ថ្ងៃម្តង ពេលមានរោគសញ្ញាដំបូង ។

ក-២ <u>ជម្ងឺបង្កឡើងដោយវីរុស:</u> មានជម្ងឺវីរុសជាច្រើនប្រភេទដែលកើតនៅលើដំណាំល្ពៅដូចជា:

-ជម្ងឺរួញគ្រួយខ្នូរឡើងលើហៅថា Squash leafcurl ដែលបណ្តាលមកពីរុយសជាភ្នាក់ងារចម្លងរោគ។

-ជម្ងឺរួញស្លឹកហើយក្រាស់ហៅថា Squash mosaic ដែលបណ្តាលមកពីខ្មុងតូចៗស្លាបរឹង និងឆ្លងតាមរយៈគ្រាប់ពូជពីមេបាដែលប្រមូលយកពូជពីដើម មានរងការបំផ្លាញដោយជម្ងឺប្រភេទនេះ ។ ជម្ងឺរួញស្លឹកក្រាស់នេះអាចកើតទៅលើផ្លែល្ពៅធ្វើឲ្យផ្លែប្រែប្រួលទម្រង់សំបកក្រាស់ខុសពីធម្មតា ហើយក្រិនមិនរីកធំធាត់ឡើយ ។

-ជម្ងឺតឿ និងពកឫសហៅថា Tobacco ringspot គេសង្កេត

ឃើញនៅក្នុងវគ្គលូតលាស់ ដើមល្ពៅប្រែពណ៌ទៅជាបៃតងក្រមៅ ហើយរួញតឿលែងលូតលាស់ឬសរបស់ល្ពៅនោះរួញ ហើយពកបណ្តាលមកពីជម្ងឺណេម៉ាតូត និងគ្រាប់ពូជពីមេបា ។

✧<u>វិធានការការពារ និង កំចាត់</u>៖ កំចាត់សត្វល្អិតជាភ្នាក់ងារចម្លងជម្ងឺ ជ្រើសរើសពូជមេបាឲ្យបានល្អ ប្តូរដី និងបំលាស់មុខដំណាំជ្រើសរើសរដូវដាំដុះ ជ្រើសរើសពូជធន់ទ្រាំ ដកដើមដែលលេចចេញសញ្ញាវីរុសទៅដុតកំទេចចោល។

***ខ-<u>សត្វល្អិតចង្រៃ</u>៖*** មានសត្វល្អិតចង្រៃជាច្រើនប្រភេទដែលស៊ីបំផ្លាញ និងចំលងមេរោគដូចនេះគេចែកចេញជា២ផ្នែក

ខ-១ <u>សត្វល្អិតភ្នាក់ងារបង្ករោគ</u>៖ សត្វល្អិតចង្រៃប្រភេទនេះមានច្រើនដូចជា ចៃបៃតងជញ្ជក់ស្លឹក មមាចជញ្ជក់ស្លឹករុយស ខ្មុំងពាលតូចៗ ជាភ្នាក់ងារចម្លងជម្ងឺវីរុសច្រើនប្រភេទ។

ខ-២<u>សត្វល្អិតបំផ្លាញផ្ទាល់</u>៖ មានសត្វល្អិតបំផ្លាញជាច្រើនប្រភេទដែលស៊ីស្លឹក ផ្កា ផ្លែ និងដើមដូចជា៖

-អណ្តើកមាសពណ៌លឿង៖ វាស៊ីត្រួយខ្ចីៗ ផ្កាឈ្មោល និងញី ធ្វើឲ្យល្ពៅបន្ថយការលូតលាស់ និងបន្តពូជ

-ស្រឹងល្ពៅ៖ វាជញ្ជក់ស្លឹក និងផ្កា ផ្លែតូចៗ ធ្វើឲ្យផ្លែលែងធំ ហើយស្អុយ លែងលូតលាស់

-រុយទិចផ្លែ៖ រុយប្រភេទនេះចាក់បញ្ចូលពងពងរបស់វា

ទៅក្នុងផ្លែ ដង្កូវរុយញាស់បំផ្លាញផ្លែធ្វើឲ្យក្រិន ឬរលួយ។

-ដង្កូវកាត់ដើម៖ ដង្កូវប្រភេទនេះកាត់គល់កូនដំណាំខ្ចីៗក្នុងវគ្គលូតលាស់ដំបូង

✦<u>វិធានការការពារ និង កំចាត់</u>៖ សំអាតស្មៅក្នុងចំការដាំឲ្យមានចន្លោះគុម្ព និងចន្លោះជួរបានសមស្រប ផ្លាស់ប្ដូរមុខដំណាំ ហាលដីឲ្យយូរខែ ជ្រើសរើសពូជឲ្យសមស្រប និងតំបន់ដាំដុះ ។ វិធានការគីមីរោយថ្នាំFuradanជុំវិញគល់ និងអាចយកថ្នាំគីមីពុលជាច្រើនប្រភេទមកលាយទឹកបាញ់ ពេលសត្វល្អិតមិនទាន់ពេញវ័យ ។

## ៤-ការប្រមូលផល

ការប្រមូលផលធ្វើឡើងខុសៗគ្នា ទៅតាមប្រភេទពូជ និងតម្រូវការទីផ្សារ ។ កាលណាគេទុកឲ្យល្ពៅទុំផ្លែដំបូងត្រូវប្រមូលមុនគេ ។ លក្ខណៈសំគាល់ គឺផ្លែល្ពៅមានពណ៌ប្រផេះស្រអាប់សំបករឹង ត្រូវកាត់ផ្លែល្ពៅទាំងទងយកមកទុកដាក់លើធ្នើរមិនប៉ះដី ទើបរក្សាបានយូរខែ ។ ទិន្នផលជាមធ្យមពី ១៤-១៦ តោន ក្នុង១ហិកតា ។

✦<u>បញ្ជាក់</u>៖ ការដាំដើម្បីយកផ្លែ មិនត្រូវកាត់ផ្កាឈ្មោលទៅប្រើប្រាស់ឲ្យអស់ច្រើននោះឡើយ ធ្វើឲ្យប្រព័ន្ធបន្តពូជខ្សោយ (ផ្លែមិនធំ ) ។

# ដំណាំឆៃថាវ

## ១-ស្ថានភាពទូទៅ



ដំណាំឆៃថាវ ឬស្ពៃមើមជាប្រភេទដំណាំម៉្យាង ដែលមានប្រជាប្រិយ៍ភាពយ៉ាងខ្លាំង នៅក្នុងការប្រើប្រាស់ជាម្ហូបអាហារប្រចាំថ្ងៃនៅប្រទេសជប៉ុន គេបានឲ្យតំលៃចាប់តាំងពីឆ្នាំ ១៩៧៤ នៅក្នុងចំណោមបន្លែជាច្រើន។ នៅប្រទេសចិនវាមានសារៈសំខាន់ជាងគេព្រោះអាចយកទៅឆ្អែជាផ្អកបាន ហៅថាឆៃប៉ូវ ។ គេបរិភោគចែកចេញជា២ប្រភេទគឺមើមឆៅ ឬចំអិន ដំណាំនេះមានប្រភពកំណើតមកពីប្រទេសចិន គេបានប្រើ

ប្រាស់វាតាំងពីឆ្នាំ១១០០មកម្ល៉េះ ដំបូងវាជារុក្ខជាតិព្រៃនៅឆ្នេរសមុទ្រមេឌីទែរ៉ាណេ ។ វាមានសារៈសំខាន់ផ្នែកការកែឆ្នៃដូចជាជ្រក់ឆៃប៉ូវជាដើម ។

## ២-បច្ចេកទេសដាំផុះ

### ក-រដូវកាលដាំផុះ

ឆៃថាវជាប្រភេទដំណាំ ដែលអាចផុះលូតលាស់មិនប្រកាន់រដូវ គេអាចដាំបានស្ទើរពេញមួយឆ្នាំ នៅក្នុងតំបន់ដែលមានអាកាសធាតុក្តៅមធ្យម ។ ប៉ុន្តែការជ្រើសរើសរដូវ វាមានទំនាក់ទំនងទៅនិងសត្វល្អិតចង្រៃស៊ីបំផ្លាញ ព្រមទាំងធ្វើឲ្យទិន្នផលថយចុះ ។ សីតុណ្ហភាពសមស្របបំផុតចន្លោះពី២០-២៥ អង្សាសេ កាលណាសីតុណ្ហភាពកើនលើសពី២៥-៣០អង្សាសេ ការផ្តល់ទឹកឲ្យបានច្រើនទើបទទួលបានទិន្នផលល្អ ។

នៅប្រទេសកម្ពុជា គេអាចដាំផុះបានល្អនៅរដូវទឹកសំរកចាប់ពីខែតុលា ដល់ខែមករា កាលណាពន្យាពេលរហូតដល់ខែកុម្ភៈ ឬខែមិនា តែងតែទទួលរងនូវការបំផ្លាញពីសត្វល្អិតចង្រៃជាច្រើន។ ចំពោះនៅតំបន់ខ្ពង់រាបគេអាចដាំបាននៅរដូវវស្សាមានលទ្ធភាពជាងរដូវប្រាំង ។

### ខ-ការជ្រើសរើសពូជ

ដំណាំប្រភេទនេះ មិនអាចផលិតពូជបាននៅក្នុង

ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដូចនេះពូជជាច្រើនបាននាំមកពីប្រទេសនានាក្នុងតំបន់អាស៊ី ដែលផលិតដោយក្រុមហ៊ុនជាច្រើន ហើយត្រូវបានពិសោធន៍វាយតម្លៃទៅលើភាពបន្សាំក្នុងលក្ខខណ្ឌប្រទេសកម្ពុជា ភាគច្រើនជាពូជអាយុកាលលូតលាស់ខ្លី និងពូជអាយុកាលលូតលាស់មធ្យម ប៉ុន្តែចំពោះពូជធ្ងន់មិនសមស្របទៅនិងលក្ខខណ្ឌនៃប្រទេសកម្ពុជាឡើយ ។ ពូជដែលត្រូវបានណែនាំឲ្យប្រើប្រាស់មាន៖

-ពូជ R6197 និងពូជ Kao yuak 18មកពីប្រទេសថៃផលិតដោយក្រុមហ៊ុន East West Seed

-ពូជ៥៥ថ្ងៃ មកពីប្រទេសថៃ ផលិតដោយក្រុមហ៊ុន Chea Tai Seed សញ្ញាយន្តហោះ

-ពូជ Everest ( $F_1$ ) មកពីប្រទេសជប៉ុន ផលិតដោយក្រុមហ៊ុន Takii Seed

-ពូជ Wong Jian មកពីសចិនហុងកុង ផលិតដោយក្រុមហ៊ុន Hong Kong Field Friend Agriculture Unite.Co ហើយកំពុងពេញនិយមទូទាំងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ២០០១ មក ។

### គ-ការជ្រើសរើស និង រៀបចំដី

គ-១ ការជ្រើសរើសដី៖ ឆៃថាវជាប្រភេទដំណាំយកមើម

ដែលលូតលាស់នៅក្នុងស្រទាប់ដីប៉ែកខាងលើ ម៉្យាងទៀតវាជាប្រភេទដំណាំដែលមានវដ្តជីវិតខ្លី ដូចនេះវាត្រូវការដីមានជីជាតិគ្រប់គ្រាន់ ។ លក្ខខណ្ឌដែលសមស្របសម្រាប់ធ្វើការដាំដុះគឺដីធូរជ្រាបទឹកបានល្អ ភាគរយដីខ្សាច់ច្រើនជាងដីកណ្ដោង ជាពិសេសដីល្បាយខ្សាច់ ដីល្បប់មាត់ទន្លេ ស្ទឹង ព្រែក ។ វាមិនអាចដុះលូតលាស់លើប្រភេទដីឥដ្ឋបានឡើយ ប៉ុន្តែវាអាចដុះលូតលាស់ល្អលើដីក្រហមខ្ពង់រាបបានដែរ ។ ជាទូទៅ PH ជាមធ្យមចន្លោះពី ៦,០-៦,៥។

គ-២ <u>ការរៀបចំដី៖</u> គេត្រូវភ្ជួររាស់ដីឲ្យបានច្រើនសារហាលដីឲ្យស្ងួត លើករងឲ្យបានខ្ពស់ កម្ពស់រងពី២៥-៣០ ស.ម, ទទឹងរងពី១០០-១២០ ស.ម បន្ទាប់មកយកជីធម្មជាតិ មកបាចលើរងឲ្យបានច្រើន ព្រមទាំងជី១៥-១៥-១៥ ៥០គ.ក្រ/ហិកតារាស់លប់ទៅក្នុងដី បន្ទាប់មកពោយថ្នាំ Furadan ៧-១០គក្រ ក្នុង ១ហិកតា ហើយស្រោចទឹកឲ្យជោគ ។

**ឃ-<u>ការដាំដុះ</u>**

ដំណាំឆៃថាវគេដាំវានឹងគ្រាប់ផ្ទាល់ ដូចនេះមុននឹងយកគ្រាប់ទៅដាំ ត្រូវយកគ្រាប់ពូជនោះដាក់ហាលថ្ងៃឲ្យក្ដៅរយៈពេល១-២ម៉ោងក្រោយមកដាក់ត្រាំទឹក៣-៤ម៉ោង ហើយលាង

សម្អាតគ្រាប់ឲ្យបានច្រើនលើក ព្រមទាំងប្រើថ្នាំផ្សិតពោយបន្តិចៗ

វិធីសាស្ត្រក្នុងការដាំដុះ គឺយកគ្រាប់ពូជទៅដាំលើថ្នាលផ្ទាល់ដោយដាក់ក្នុងជំរៅ២ស.ម ជាមធ្យមដាក់២គ្រាប់ក្នុង១គុម្ព ហើយចន្លោះជួរ និងគុម្ព២០ស.ម x ២០ស.ម ក្រោយពីដាំរួច ត្រូវយកចំបើងស្ងួតទៅគ្របពីលើផ្ទៃរង ឲ្យបាន៧០-៨០% ដើម្បីការពារសំណើម និងភាពហាប់ណែននៃដី ជួយឲ្យផៃថាវដុះលូតលាស់បានល្អ ប៉ុន្តែក្រោយពីដាំត្រូវស្រោចទឹកឲ្យជោគភ្លាមៗ ។

ង-<u>ការស្រោចស្រព</u>

ការផ្តល់ទឹកបានគ្រប់គ្រាន់ និងទៅតាមតម្រូវការរបស់វាធ្វើឲ្យដំណាំដុះលូតលាស់លឿន ប៉ុន្តែសេចក្តីត្រូវការមិនដូចគ្នាទាំងស្រុងនោះឡើយ គឺអាស្រ័យទៅតាមវគ្គលូតលាស់របស់វាដូចតទៅ៖

-វគ្គដុះពន្លក៖ នៅក្នុងវគ្គនេះចាប់ពីពេលដាំរហូតដល់ផៃថាវដុះ១០០% វាត្រូវការសំណើមដីថេរ តែមិនជោគជាំខ្លាំងកាលណាដីស្ងួតបណ្តាលឲ្យដីក្តាំង ធ្វើឲ្យដំណុះមិនស្មើគ្នាព្រមទាំងបាត់បង់ចំនួនដើមច្រើន ដូចនេះគេត្រូវផ្តល់ទឹកព្រឹកល្ងាចតាមវិធីសាស្ត្រជាច្រើន ដែលអាចធ្វើទៅបានដោយប៉ោត ដោយ

ម៉ាស៊ីន ។ នៅក្នុងវគ្គនេះកាលណាសំណើមដីសើមខ្លាំងលើស សេចក្ដីត្រូវការ ធ្វើឲ្យកូនដំណាំរលួយឫសទៅវិញ ។

-វគ្គលូតលាស់ស្លឹកពិត៖ ក្រោយពីដុះពន្លក១០០% រយៈពេល ៧-១០ថ្ងៃ ដៃថាវដុះបានស្លឹកពិត២-៣សន្លឹកវាត្រូវការទឹកកំរិតមធ្យមប្រហែលគ្នានឹងវគ្គដុះពន្លកដែរ ប៉ុន្តែទាបជាងបន្តិច កាលណាស្រោចទឹកខ្លាំងសំណើមដីខ្ពស់ ធ្វើឲ្យគល់កូនដៃថាវប្រេះអាចធ្វើឲ្យយឺតយ៉ាវ ក្នុងវគ្គកំណកំណើតមើម ។

-វគ្គកំណកំណើត និងពង្រីកមើម៖ ក្រោយពីដាំបានរយៈពេល១៥-១៨ថ្ងៃ គេសង្កេតឃើញដៃថាវចាប់ផ្ដើមពង្រីកគល់ប៉ោងបន្តិចៗ ពេលនោះវាត្រូវការទឹក និងសារធាតុចិញ្ចឹមកាន់តែកើនឡើងៗ រហូតដល់ពេលប្រមូលផល ដូចនេះត្រូវបង្កើនការស្រោចទឹកឲ្យខ្លាំងជាងវគ្គនានា អាចធ្វើឲ្យទិន្នផលដៃថាវកាន់តែកើនឡើង ។

ច-<u>ការជ្រុំជ្រោយដី និងដកស្មៅ</u>

ដើម្បីឲ្យដីធូរ ព្រមទាំងទប់ស្កាត់ការដុះលូតលាស់នូវស្មៅចង្រៃ នឹងការលូតលាស់ប្រព័ន្ធឫសដំបូង ត្រូវដករំលួសកូនដៃថាវចេញទុកតែ១ដើម/គុម្ព ព្រមទាំងដកស្មៅចេញ ហើយយកកូនចបមុខតូចជ្រុំដីឲ្យផុសក្បែរៗគុម្ពពេញផ្ទៃរង ហើយផ្អាកការស្រោចទឹក១ថ្ងៃ ធ្វើឲ្យដីនោះស្ងួតមានខ្យល់ចេញចូលបាន

ល្អ ។ រយៈពេលសមស្របក្នុងការជ្រុំជ្រោយដី គឺធ្វើឡើងក្រោយពីដាំបានចំនួន១៥-១៨ថ្ងៃ កាលណាពន្យាពេលជ្រុំជ្រោយដីទុកឲ្យផ្លែថាវពង្រីកមើមកាន់តែធំ អាចរំខានដល់ការវិវឌ្ឍន៍នៃប្រព័ន្ធឫសរបស់វាធ្វើឲ្យមើមតូចហើយខ្លី ។

**ឆ-<u>ការដាក់ជី</u>**

ផ្លែថាវជាប្រភេទដំណាំ ត្រូវការជីជាតិច្រើន ព្រមទាំងសារធាតុរ៉ែផ្សេងៗ ជាពិសេសគឺធាតុអាសូត (N) ផូស្វ័រ(P) ប៉ូតាស្យូម (K) និងកាល់ស្យូម (Ca) ដូចនេះការដាក់ជី ត្រូវជ្រើសរើសប្រភេទជីណាដែលមានសារធាតុN, P, K និង Ca ដើម្បីឲ្យមានធាតុ Ca គេច្រើនប្រើជីលាមកសត្វ ជាពិសេសជីលាមកមាន់ ដាក់មុនពេលដាំចំនួន៨-១០តោនក្នុង១ហិកតា ក្រៅពីនោះទៀត គេអាចប្រើជីលាមកជ្រូកពុកផុយយូរឆ្នាំក៏បាន។

ការផ្តល់ជីចែកចេញជា៤លើកគឺ៖

-លើកទី១:ប្រើជីអ៊ុយរ៉េលាយទឹកស្រោច ដោយប្រើចំនួន២៥-៣០ក្រាម លាយទឹក២០លីត្រ លើផ្ទៃដី១០ម$^{2}$ហើយស្រោចទឹកលាងតាមក្រោយ ១ហិកតាគេប្រើជីទម្ងន់២៥-៣០គ.ក្រ រយៈពេល១០ថ្ងៃក្រោយដាំ ។

-លើកទី២ : ប្រើជី ១៥-១៥-១៥ ចំនួន២០០ក្រាម លើផ្ទៃ

ដី១០ម² ១ហិកតាគេប្រើជីទំងន់២០០គ.ក្រ ដាក់ក្រោយពេលជ្រុំជ្រោយដី១៥-១៨ថ្ងៃក្រោយដាំ វិធីសាស្រ្តគឺដាក់ចន្លោះគុម្ពហើយជ្រុំដីលុបឲ្យជិត។

-លើកទី៣ :ប្រើជីអ៊ុយរ៉េចំនួន៤០-៥០ក្រាមលាយទឹក២០លីត្រ ស្រោចឲ្យជោគលើផ្ទៃដី១០ម² ហើយស្រោចទឹកលាងតាមក្រោយ រយៈពេល២០-៣០ថ្ងៃក្រោយដាំ។

-លើកទី៤: គេប្រើជី២ប្រភេទរួមគ្នាក្នុងករណីធ្វើទៅបានគឺជីអ៊ុយរ៉េចំនួន ៣០គ.ក្រ និងជីប៉ូតាស្យូមចំនួន៥០គ.ក្រ លាយបញ្ចូលគ្នា ហើយដាក់តាមចន្លោះគុម្ព រយៈពេល៤០ថ្ងៃ ក្រោយពីដាំធ្វើឲ្យផ្លែថាវមើមធំ ហើយមានគុណភាពល្អ ។

## ៣-សត្វល្អិតចង្រៃ និងវិធានការពារ

-ដង្កូវឃោលទោង: Diamond back moth ជាសត្រូវយ៉ាងចំបង វាស៊ីបំផ្លាញជាលិកាស្លឹក ធ្វើឲ្យស្លឹកផ្លែថាវលែងល្អតលាស់បាន ហើយបាត់បង់ ១០០% ។ នៅប្រទេសកម្ពុជាយើងការបំផ្លាញច្រើនចាប់ផ្តើមពីចុងខែមករា រហូតដល់ខែឧសភាក្រៅពីនេះវត្តមានរបស់វាត្រូវថយចុះមកវិញ ។ ដើម្បីការពារនិងកំចាត់ដង្កូវប្រភេទនេះគេត្រូវសិក្សាអំពីវត្តមាន មេចំណាស់របស់វាគឺមេអំបៅ កាលណាមានមេអំបៅហើរ ក្នុងចំការនៅពេលល្ងាចមិនយូរទេនិងមានដង្កូវស៊ីបំផ្លាញ ដូចនេះគេត្រូវរកវិធីទប់

ទល់ជាមុន ទៅតាមលក្ខណៈដែលអាចធ្វើទៅបាន ជាពិសេសតាមវិធានការគីមី ។

-ដង្កូវស៊ីរូងកំពូលៈ Cabbage head caterpillar វាមានមាឌតូចៗប្រហែលនឹងដង្កូវឃោលទោងដែរ តែមានមាឌធំ ហើយវែងជាងមានពណ៌ប្រផេះមានពោមបន្តិចៗ វាស៊ីស្លឹកដោយពុំបន្សល់ទុកនូវភ្នាសអេពីឌែម ដូចដង្កូវឃោលទោងឡើយ ព្រមទាំងលក្ខណៈជាហ្វូងផ្តុំនៅនឹងត្រួយ ។

-ដង្កូវកាត់ដើមៈ Black cut worm ដង្កូវមានមាឌធំវែងៗពណ៌ខ្មៅ ច្រើនជ្រកពួននៅក្នុងដីចំការដំណាំ មេអំបៅរបស់វាពងដាក់លើស្មៅ ឬដីមុនពេលដាំដំណាំ ក្រោយពីដំណាំដុះ ក្នុងតំណាក់កាលកូនសំណាបវាចាប់ផ្តើមញាស់ ហើយកាត់ស៊ីជាចំណីអាហាររបស់វានៅពេលយប់ វាធ្វើឲ្យបាត់បង់ចំនួនដើមច្រើនក្នុងចំការដាំដុះ។

-សត្វទាកគូរៈ Flea beetle វាជាសត្វល្អិតចង្រៃយ៉ាងខ្លាំង ព្រោះក្នុងមួយវដ្តជីវិតរបស់វាចាប់ពីកូនញាស់ដល់មេចំណាស់ ត្រូវស៊ីបំផ្លាញដំណាំជាប្រចាំដូចជា៖

➤ដំណាក់កាលកូនញាស់ៈ មេចំណាស់ពងដាក់លើថ្នាលក្បែរគល់ដំណាំ ក្រោយពីវាញាស់ទៅជាកូនដង្កូវតែងតែស៊ីបំផ្លាញឫស និងមើមឆៃថាវដែលកសិករខ្មែរយើងហៅថាកណ្តៀ

ដីស៊ី ធ្វើឲ្យដំណាំស្រពោនបន្ថយការលូតលាស់ដើមត្រូវខូចខាតយ៉ាងខ្លាំង ជាពិសេសនៅរដូវក្តៅ ។

➤ដំណាក់កាលពេញវ័យ: មេចំណាស់តូចៗមានស្លាបរឹងប៉ុនៗជើងធូប លក្ខណៈជាក្រុមៗ លោតដោយផ្ទាត់ជើងរបស់វា សត្វនេះស៊ីទំលុះស្លឹក ធ្វើឲ្យស្លឹករទុះៗដូចស្បៃស្លឹកក្រិនលែងលូតលាស់អាចធ្វើឲ្យបាត់បង់ទិន្នផលយ៉ាងច្រើន ក្នុងមួយឆ្នាំៗ ការបំផ្លាញខ្លាំងចាប់ពីខែកុម្ភៈ រហូតដល់ខែមេសា ជារៀងរាល់ឆ្នាំ ។

✦ដើម្បីការពារ និងកំចាត់ដង្កូវប្រភេទនេះគេត្រូវអនុវត្តវិធានការយ៉ាងច្រើនដូចជា៖

-ការផ្លាស់ប្តូរដី: មិនត្រូវដាំឆៃថាវក្រោយពីដាំដំណាំអំបូរ Cruciferឡើយ ត្រូវបាចថ្នាំប្រភេទ Furadan ក្នុងកំរិត១០-១៥Kg ក្នុង១ហិកតា ហើយភ្ជួរលប់ក្រោយពីប្រមូលផលឆៃថាវរួច ។

-ការជ្រើសរើសរដូវ: រដូវមានទំនាក់ទំនងគ្នាជានិច្ចទៅ និងការកកើតកត្តាចង្រៃ ព្រោះវាតែងពង្រីកពូជពង្សរបស់វានៅរដូវក្តៅ ហើយដំណាំមិនទាមទារនូវសីតុណ្ហភាពក្តៅខ្លាំងឡើយ ។

-ការធ្វើអនាម័យចំការ: សំអាតស្មៅទាំងក្នុង និងជុំវិញចំការឲ្យបានស្អាត ពីព្រោះវាជាជំរករបស់ភ្នាក់ងារចង្រៃ ។

-ការអនុវត្តវិធានការគីមី: ក្នុងករណីមានដង្កូវ៤ប្រភេទខាងលើ គេត្រូវប្រើប្រាស់ថ្នាំគីមីកសិកម្មក្នុងការកំចាត់ដូចជា

យកមកលាយទឹកបាញ់ ឬបាចទៅក្នុងថ្នាល ពេលសត្វល្អិតស្ថិតក្នុងតំណាក់កាលកូនញាស់ទើបមានប្រសិទ្ធភាពល្អ ។

## ៤-ការប្រមូលផល

ការប្រមូលផលត្រូវគិតអំពីវដ្តជីវិតរបស់វា ព្រមទាំងតម្រូវការទីផ្សារ កាលណាដកមើមឆៃថាវ មិនទាន់គ្រប់អាយុកាលត្រឹមត្រូវធ្វើឲ្យបាត់បង់ទិន្នផល ព្រមទាំងមិនអាចរក្សាទុកបានយូរផងដែរព្រោះវាខ្ចីពេក ប៉ុន្តែបើកាលណាពន្យាពេលដកធ្វើឲ្យមើមឆៃថាវចាស់ស្អោត ហើយអាចបាត់បង់ទិន្នផល និងគុណភាពផងដែរ ។ ដូចនេះដើម្បីប្រមូលផលទៅតាមស្តង់ដារ គឺ គេពិនិត្យមើលទៅលើពណ៌នៃស្លឹក វាប្រែពណ៌ពីបៃតងខ្ចី ទៅពណ៌បៃតងចាស់កំពូលត្រួយរបស់វាលែងលូតលាស់ ដើមប្រែពណ៌ពីសខ្ចីទៅសប្រផេះ ហើយរលោងគ្មានជាប់ឬសពេលដកនោះជាតំណាក់កាលត្រូវប្រមូលផល ។

របៀបប្រមូលផល គឺដកយកមើមឆៃថាវដាក់តំរៀបនៅនឹងចំការ ក្រោយមកកាត់ស្លឹកចេញហើយជញ្ជូនទៅកាន់ទីត្រជាក់ មិនត្រូវដាក់ហាលថ្ងៃឡើយ។ កាលណាគេបញ្ជូនទៅកាន់ទីផ្សារជិតៗត្រូវលាងទឹកសំអាតមើមជាមុន ប៉ុន្តែក្នុងករណីត្រូវដឹកទៅកាន់តំបន់ឆ្ងាយៗមិនត្រូវលាងទឹកឡើយ ព្រោះអាចបណ្តាលឲ្យជាំរលួតសំបកទុកមិនបានយូរ។ ជាធម្មតាទិន្នផលជាមធ្យមទៅតាមប្រភេទពូជ និងរដូវកាលដាំដុះប៉ុន្តែទោះជាយ៉ាង

ណានៅក្នុងប្រទេសកម្ពុជាយើង អាចទទួលបានទិន្នផលពី ២៨-៣២តោន ក្នុង១ហិកតា។

## ៥-ការកែច្នៃផលិតផល

ដើម្បីរក្សាទុកផលិតផលឆៃថាវបានយូរខែ គេអាចកែច្នៃធ្វើជាផ្អកឆៃថាវ ហៅថាឆៃប៉ូវរបៀបធ្វើមានៈ ទម្ងន់មើមស្រស់ ១០០គ.ក្រ អំបិលម៉ត់២០គ.ក្រ។ យកមើមឆៃថាវចាស់មកលាងទឹកឲ្យស្អាតកាត់ក្បាលមើមចេញហើយពុះជា២ ដាក់ហាលថ្ងៃឲ្យស្រពោន១ថ្ងៃ បន្ទាប់មកតំរៀបក្នុងពាងកំរាស់១០ស.ម រោយអំបិលម៉ត់បន្តិចៗ រហូតដល់ពេញពាងហើយសង្កត់មើមឆៃថាវឲ្យជាប់ផ្អាប់រយៈពេល២ថ្ងៃ ទើបយកចេញហាល ។ ហាលរយៈពេល២ថ្ងៃ យកទៅត្រាំក្នុងទឹកអំបិលដដែល១យប់ ធ្វើរបៀបនេះ រហូតដល់មើមឆៃថាវស្វិតស្រពោនប្រែពណ៌ពីមើមឆៃថាវទៅឆៃប៉ូវ ។ ពេលនោះគេអាចយកទៅរក្សាទុកក្នុងពាង ឬធុងជ័របាន ។ ប៉ុន្តែដើម្បីយកមកប្រើ ឬច្នៃជាឆៃប៉ូវផ្អែម គេអាចយកឆៃប៉ូវមកច្នៃបន្ថែម គឺលាងទឹកអោយស្អាតថ្លឹងទំងន់របស់វាតាមសមាមាត្រគឺ១០គ.ក្រឆៃប៉ូវៈ ស្ករចំនួន០.៥គ.ក្រ, ទឹក៥គ.ក្រ, អំបិល០.៥គ.ក្រ ដាំឲ្យពុះទុកឲ្យត្រជាក់ ហើយយកឆៃប៉ូវមកដាក់ត្រាំរយៈពេលពី២-៣ថ្ងៃ ហើយយកមកហាលថ្ងៃឲ្យបាន១-២ថ្ងៃ អាចចិតជាចំណិតតូចៗ មកបរិភោគបាន។

# ឯកសារយោង

១-សៀវភៅណែនាំអំពីការគ្រប់គ្រងសត្វល្អិត និងជម្ងឺលើដំណាំបន្លែភាគ ២, គម្រោងQCAM(JICA) ឆ្នាំ២០១២

២-សៀវភៅណែនាំ អំពីការគ្រប់គ្រងសមាសភាពចង្រៃ, គម្រោងQCAM (JICA) ឆ្នាំ២០១១

៣-ឯកសារជំនួយបច្ចេកទេសដំណាំបន្លែvvob,ឆ្នាំ២០១១

៤-បច្ចេកទេសដាំដំណាំបន្លែ, អគ្គនាយកដ្ឋានកសិកម្ម ឆ្នាំ២០១១

៥-បច្ចេកទេសដាំបន្លែសម្រាប់មន្ត្រីផ្សព្វផ្សាយ, នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង ក្រុមហ៊ុន EAST-WEST SEED INTERNATIONAL

៦-គោលការណ៍ណែនាំ សម្រាប់ធ្វើអត្តសញ្ញាណកម្ម និងការគ្រប់គ្រងជម្ងឺលើដំណាំបន្លែ IPM, ២០០៨

៧-សត្វល្អិត និ ងជម្ងឺលើដំណាំអំបូរស្ពៃ, លោក ម៉ុង វ៉ាន់ឌី ស្ថានីយ៍ក្បាលកោះ ឆ្នាំ២០០៤

៨-ដំណាំបន្លែនៅកម្ពុជា, លោក ម៉ុង វ៉ាន់ឌី ស្ថានីយ៍ក្បាលកោះឆ្នាំ២០០២

៩-គេហទំព័រCEN